# កម្ពុជាក្រោម

ព្រឹត្តិបត្រពោះពុម្ពផ្សាយជារៀងរាល់ខែ ដោយសហព័ន្ធខ្មែរកម្ពុជាក្រោម

លេខ ១៤ ឆ្នាំទី ០២ - ខែកុម្ភៈ គ.ស. ២០០៥ - ព.ស. ២៥៤៨ - N° 14, February, 2005


# សន្និបាតសហព័ន្ធខ្មែរកម្ពុជាក្រោម ឆ្នាំ ២០០៥




*លោក ថាច់ ង៉ុកថាច់ ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម*



*សមាជិក សមាជិកា សហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្នុងអង្គសន្និបាត*

សហព័ន្ធខ្មែរកម្ពុជាក្រោម រួមជាមួយនឹងសមាជិក សមាជិកា មកពីជុំវិញពិភពលោក បានប្រារព្ធធ្វើសន្និបាតបូកសរុបការងារ និង រៀបចំផែនការ ៣ ឆ្នាំ (២០០៥-២០០៧) កាលពីថ្ងៃទី ០១-០២ ខែ មករា ឆ្នាំ ២០០៥ កន្លងទៅនេះ នៅទីក្រុងឡង់ប៊ិច រដ្ឋកាលីហ្វរញ៉ា ។ អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីរួមមាន ភ្ញៀវជាតិ អន្តរជាតិ និង អ្នកសារព័ត៌មានជាតិ អន្តរជាតិយ៉ាងច្រើនកុះករ ។

អង្គសន្និបាត ចាប់ដំណើរការបន្ទាប់ពីសមាជិក-សមាជិកា គោរពវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរ និងមនុស្សជាង ២០០ ពាន់នាក់ នៃ ប្រទេសទាំង ១២ ដែលបានស្លាប់ដោយមហន្តរាយនៃគ្រោះធម្មជាតិ (មហារលកយក្សស៊ូណាមិ) ក្នុងតំបន់មហាសមុទ្រឥណ្ឌា ។ ក្រោយពីពិនិត្យរបាយការណ៍ និងបូកសរុបការងារសព្វជ្រុងជ្រោយ ហើយ សហព័ន្ធបានដាក់ចេញនូវផែនការជាយុទ្ធសាស្ត្រ ចម្បង ក្នុងគោលដៅសង្គ្រោះបងប្អូនខ្មែរនៅកម្ពុជាក្រោម ឲ្យបានសម្រេច តាមបំណងប្រាថ្នា គឺ "សម្រេចវាសនាខ្លួនដោយខ្លួនឯង" ។ ក្នុងនោះ គឺផ្តោតលើយុទ្ធសាស្ត្រសំខាន់៣ ៖ ទី១ កម្លាំងមនុស្ស ទី២ កម្លាំងសេដ្ឋកិច្ច និង ទី៣ កម្លាំងគាំទ្រពីសំណាក់អន្តរជាតិ ។

## មាតិការឿង


- សន្និបាតសហព័ន្ធ.......................................១
- យួនកំពុងបំផ្លិចបំផ្លាញប្រពៃណី.................៣
- ឆ្នាំព្រំដែនយួនបិទមិនឲ្យព្រះសង្ឃ...............៤
- ពិធីបុណ្យអុំទូក អកអំបុក..........................៤
- រមណីដ្ឋានស្រះគូកំពុងរង..........................៥
- លិខិតអំពាវនាវរបស់សហព័ន្ធ.....................៦
- រឿងកំពប់តែអុង........................................៨
- ប្រមាទ និងមិនប្រមាទ..............................១១
- ឈាមទឹកភ្នែកនៅព្រែកបាត្រាច...............១២
- រឿងទុក្ខម្នានិកៈ......................................១៣
- របាយការណ៍រំលោភសិទ្ធិមនុស្ស..............១៦


**១-កម្លាំងមនុស្ស ៖**

តាមប្រសាសន៍របស់លោក តោ គឹមថុង អធិបតីសហព័ន្ធ បានថ្លែងក្នុងអង្គសន្និបាតថា កម្លាំងមនុស្សជាកម្លាំងជួរមុខវិសេសវិសាលណាស់ ដែលសហព័ន្ធបាននិងកំពុងប្រឹងប្រែងយ៉ាងពេញទំហឹង ជួយដល់បងប្អូនខ្មែរនៅក្នុងស្រុកឲ្យយល់ច្បាស់ថែមទៀត នូវសិទ្ធិជាម្ចាស់ស្រុក ដែលអាចសម្រេចជ្រើសភ័ព្វវាសនារបស់ខ្លួនដោយខ្លួនឯងបាន ។ ជំហានដំបូង ដើម្បីឲ្យបងប្អូនម្ចាស់ស្រុកយល់ច្បាស់នូវសិទ្ធិស្របច្បាប់របស់ខ្លួន គឺគួរតែជម្រុញសកម្មភាពសិក្សាអប់រំចំណេះដឹងពីពិភពលោកខាងក្រៅ ឲ្យជ្រួតជ្រាបចូលទៅដល់ភូមិស្រុកនានានៃកម្ពុជាក្រោម ។

ថ្លែងបញ្ជាក់បន្ថែមពីយុទ្ធសាស្ត្ររបស់លោកអធិបតី តោ គឹមថុង លោក ថាច់ ង៉ុកថាច់ ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម បានគូសបញ្ជាក់ថា សហព័ន្ធបាននឹងបម្រុងនូវឯកសារ សម្ភារៈសំខាន់ៗ មួយអន្លើ ដោយសកម្មជនសហព័ន្ធ ដើម្បីជួយការងារខ្លះដល់បងប្អូនខ្មែរនៅក្នុងស្រុក ។ ឯរឿងត្រូវតែកោតសរសើរ ដែលបងប្អូនខ្មែរនៅក្នុងស្រុកកំពុងជួយខ្លួនឯងនោះ គឺថែរក្សានូវអត្តសញ្ញាណរបស់ខ្លួន ទាំងសម្លៀកបំពាក់ ប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រ និងសំនៀងភាសាផងដែរ ។

**២-កម្លាំងសេដ្ឋកិច្ច ៖**

អង្គសន្និបាតបានឲ្យដឹងថា ថវិកាចំណូលចំណាយសម្រាប់ទ្រទ្រង់ការងារសហព័ន្ធ និងការឧបត្ថម្ភដល់ការសិក្សារៀនសូត្រនៃយុវជនជាកូនចៅខ្មែរក្រោម ដែលជាទំពាំងស្នងឫស្សីដ៏សំខាន់នាពេលអនាគត ព្រមទាំងការឧបត្ថម្ភដល់ជនរងគ្រោះខ្មែរក្រោម ដោយមូលហេតុផ្សេងៗ មួយចំនួន ទាំងក្នុងនិងក្រៅស្រុកនោះ ជាខ្ទង់ចំណូលចំណាយដែលបានមកដោយការបង់វិភាគទាន ពីសំណាក់សមាជិក



*សមាជិក សមាជិកា សហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្នុងអង្គសន្និបាត*

សហព័ន្ធ ហើយមួយផ្នែកទៀតបានមកពីការឧបត្ថម្ភរបស់បងប្អូនសប្បុរសជនខ្មែរ-ខ្មែរក្រោម ពីសំណាក់បងប្អូនជាតិសាសន៍ដទៃទៀត ព្រមទាំងការធ្វើវិនិយោគរបស់សហព័ន្ធ ។

សម្រាប់យុទ្ធសាស្ត្រសេដ្ឋកិច្ចនៃគម្រោងថ្មីនេះ គឺការខិតខំប្រឹងប្រែងឲ្យប្រជាជាតិជាមិត្ត បណ្ដាប្រទេសស្នេហាយុត្តិធម៌ សន្តិភាព ជួយឧបត្ថម្ភដល់សហព័ន្ធ តាមរយៈអង្គការអន្តរជាតិនានា ពិសេសអង្គការ UNPO ជាកត្តាមួយដែលសហព័ន្ធសង្ឃឹម និងមិនអាចខកខានបាន ។

**៣-កម្លាំងគាំទ្រពីសំណាក់អន្តរជាតិ ៖**

តាមរយៈសុន្ទរកថារបស់លោក ប្រាក់ សេរីវុឌ្ឍ អនុប្រធានប្រតិបត្តិសហព័ន្ធ ក្នុងអង្គសន្និបាតបានឲ្យដឹងថា សព្វថ្ងៃខ្មែរក្រោម (សហព័ន្ធ) មានប្រជាជាតិជាមិត្តប្រមាណជា ៦០ ជនជាតិ នៅក្នុងអង្គការ UNPO ក្រៅពីនេះ ក៏នៅមានអង្គការអន្តរជាតិ ប្រជាជាតិ ប្រទេសជាតិដទៃជាច្រើនទៀតលើសកលលោក ដែលស្រឡាញ់សន្តិភាព យុត្តិធម៌ ប្រឆាំងនឹងរបបកុម្មុយនិស្ត ពិសេសកុម្មុយនិស្តយួន មានសហរដ្ឋអាមេរិកជាដើម ដែលបានគាំទ្រយើង និងគាំទ្រយើងជាងនេះទៀតនាពេលអនាគត ។

ថ្លែងក្នុងអង្គសន្និបាតនេះ លោក សឺន ទូន ឧត្តមទីប្រឹក្សាសហព័ន្ធខ្មែរកម្ពុជាក្រោម បានគូសបញ្ជាក់ពីក្ដីសង្ឃឹមយ៉ាងមុតមាំរបស់ខ្មែរក្រោមថា សហព័ន្ធខ្មែរកម្ពុជាក្រោមកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងគណៈកម្មការកណ្ដាល ដែលមានសមាជិកតំណាងឲ្យជនជាតិ ៤ ដើម្បីរៀបចំការកែទម្រង់កិច្ចប្រតិបត្តិការនៃអង្គការ UNPO នាពេលខាងមុខ ។ លោកបន្តទៀតថា តំណាងជនជាតិទាំង ៦ នៃអង្គការ UNPO បានទទួលឯករាជ្យពេញលេញហើយ ហើយបានក្លាយជាសមាជិកពេញលក្ខណៈនៃអង្គការសហប្រជាជាតិរួចហើយ ក្រោយពីការកើតឡើងនៃអង្គការ UNPO នេះ ។ តំណាងជនជាតិទាំង៦ នោះគឺ ទីម័រខាងកើត អេស្តូនៀ ចូចចើ ឡាតធ្វា អាមីនៀ និងបាឡៅ ។ ហើយនិងនៅមានតំណាងជនជាតិ ៧ ទៀតជាសមាជិក UNPO កំពុងធ្វើការទាមទារឯករាជ្យរបស់ខ្លួនយ៉ាងសកម្ម ។ តំណាងជនជាតិទាំង ៧ នោះរួមមាន ទីបេ តៃវ៉ាន់ អាចេស៍ ប៉ាពួខាងលិច (កោះស្មៀ) ណាហ្គាលីញ កូស៊ូ និងឆេកឆៀរ ។

លោកបណ្ឌិត ចូស្វ័រ យូបផើរ (Joshua Cooper) នាយកវិទ្យាស្ថានសិទ្ធិមនុស្សទីក្រុងហាវ៉ៃ និងជាឧត្តមទីប្រឹក្សាអង្គការ UNPO បានកោតសរសើរចំពោះសកម្មភាពល្ងតលាស់យ៉ាងឆាប់រហ័សរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ហើយលោកបានឲ្យដឹងទៀតថា យ៉ាងហោចណាស់ ក៏មានសកម្មភាពជាលក្ខណអន្តរជាតិចំនួន ៨ លើកដែរ ដែលសហព័ន្ធនឹងត្រូវចូលរួមចាប់ពីខែមិនា ដល់ខែតុលា នេះ ។ សកម្មភាពទាំងនោះ មានដូចជា ការចូលរួមដង្ហែក្បួនទិវានារីអន្តរជាតិ ៨ មីនា និងទិវាខួបឆ្នាំទី ៦០ (២៥ តុលា ១៩៤៥- ២៥ តុលា ២០០៥) ការកើតឡើងនៃអង្គការគ្រួសារពិភពលោក ឬ អង្គការសហប្រជាជាតិជាដើម ។

លោកបណ្ឌិតបន្តថា កាលពី ៦០ ឆ្នាំមុន អង្គការពិភពលោកនេះមានសមាជិកតែ ៥០ ប្រទេសប៉ុណ្ណោះ ប៉ុន្តែឥឡូវសមាជិកនៃអង្គការនេះ មានរហូតដល់ទៅ ១៩១ ប្រទេស ។

លោកបណ្ឌិតមានសង្ឃឹមថា អង្គការគ្រួសារពិភពលោកនេះពិតជាអាចបើកទ្វារឲ្យសមាជិកថ្មីមួយទៀត ពោលគឺខ្មែរក្រោម អាចចូលរួមក្នុងគ្រួសារសកលនេះបានជាពុំខាន ។

ចំណែកលោក ផីតធី ស្កត់ (Peter Scott) អតីតទាហានអាមេរិកាំងក្នុងសង្គ្រាមវៀតណាម លោកបានចែករំលែកនូវបទពិ-សោធន៍របស់លោក រួមជាមួយមិត្តភ័ក្តិខ្មែរក្រោម ដែលបានរួមគ្នាតស៊ូប្រឆាំងនឹងរបបកុម្មុយនិស្ត ក្នុងសង្គ្រាមវៀតណាម ។ លោកបានថ្លែងថា ៖ "ខ្ញុំសូមកោតសរសើរយ៉ាងខ្លាំងចំពោះប្រជាពលរដ្ឋខ្មែរក្រោម ដែលមានគ្នាតិចតួចសោះ បើប្រៀបធៀបទៅនឹងជាតិសាសន៍ដទៃ តែមានទឹកចិត្តអង់អាចក្លាហានជាងជាតិសាសន៍ទាំងនោះ ...ថ្ងៃនេះប្រសើរណាស់ដែលបងប្អូនស្រុះស្រួលគ្នា ក្រោកឡើងទាមទារសិទ្ធិសេរីភាពជូនបងប្អូនខ្មែរក្រោម ដែលកំពុងទទួលរងនូវការជិះជាន់សង្កត់សង្កិនពីសំណាក់យួនកុម្មុយនិស្តនៅឯកម្ពុជាក្រោម" ។ សង្កថារបស់លោកស្កត់ បានបញ្ចប់ទៅដោយភាពក្ដុកក្ដួល និងស្នូរទះដៃអបអរយ៉ាងគ្លៀវក្លា ។

ចំណែកអ្នកស្រី សឺន ធីនិត ជាស្ត្រីខ្មែរក្រោមមួយរូប និងជាតំណាងស្ត្រីខ្មែរក្រោម បានសម្ដែងនូវចំណាប់អារម្មណ៍របស់ខ្លួនថា ៖ "ដើម្បីសហព័ន្ធខ្មែរកម្ពុជាក្រោម ស្ត្រីខ្មែរក្រោមអាចធ្វើអ្វី ៗ បានទាំងអស់ ដូចជាស្ត្រីទូទៅក្នុងពិភពលោកអីចឹងដែរ" ។

អង្គសន្និបាត បានចប់សព្វគ្រប់នៅរាត្រីថ្ងៃទី ២ មករា ប្រកបដោយលទ្ធផលផ្លែផ្កាជាវិជ្ជមាន និងស្នាមញញឹមបញ្ជាក់ពី ភាតរភាព សាមគ្គីភាព ភក្ដីភាព ពោរពេញដោយឆន្ទៈ "ខ្មែរ ជួយ ខ្មែរ" ចូលរួមគាំទ្រលើកស្ទួយសហព័ន្ធខ្មែរកម្ពុជាក្រោមឲ្យឈានទៅដល់ "សម្រេចវាសនាខ្លួនដោយខ្លួនឯង" លើមាតុភូមិកម្ពុជាក្រោម សមតាមបំណងប្រាថ្នារបស់ខ្មែរគ្រប់ ៗ រូប ៕

និពន្ធនាយក ៖ **ថាច់ ប៉ុកថាច់** ផ្សព្វផ្សាយ ៖ **សឺន រតនៈ, ថាច់ សែន, សឺន ច័ន្ទ**
ឯកសារ PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

# យួនកំពុងបំផ្លិចបំផ្លាញប្រពៃណី និង លុបដានប្រវត្តិសាស្ត្រខ្មែរ

ខ្មែរក្រោមបានតាំងទីលំនៅដំណាលគ្នានឹងការកកើតឡើងនៃវាលភក់ល្បាប់នៃដែនដីកម្ពុជាក្រោម ។ ខ្មែរក្រោមជាម្ចាស់ដើមនៃមាតុភូមិកម្ពុជាក្រោម ដែលជាចំណែកមួយនៃភូមិភាគវៀតណាមខាងត្បូងសព្វថ្ងៃ ។

ខ្មែរក្រោមមានអរិយធម៌ដ៏ឧត្តមនៅលើមាតុភូមិរបស់ខ្លួន ។ ខ្មែរក្រោមមានវត្តជាង ៥០០ ដែលវត្តខ្លះមានអាយុកាលជិតមួយពាន់ឆ្នាំមកហើយមានជាអាទិ៍ ដូចជាវត្តសំបួររង្សី ស្ថិតក្នុងខេត្តព្រះត្រពាំង ដែលខ្មែរ បានកសាងឡើងក្នុងគ.ស. ៣៧៣ ។ វត្តពោធិសាលរាជ (កំពង់) ក្នុងខេត្តព្រះត្រពាំង កសាងឡើងក្នុង គ.ស. ៦៤២ ។ល។

ខ្មែរក្រោមមានរមណីយដ្ឋានជាតិបុរាណជាច្រើន ដូចជារមណីយដ្ឋានស្រះគូ នៅខេត្តព្រះត្រពាំង កសាងឡើងក្នុងសតវត្សរ៍ទី ៧ ។ ប្រាសាទព្រះធាតុ នៅខេត្តពលលាវ កសាងនៅសតវត្សរ៍ទី ៩ ប្រាសាទប្រាំល្វែង នៅខេត្តទឹកខ្មៅ កសាងនៅសតវត្សរ៍ទី ៦ និងមានកេតនភ័ណ្ឌជាតិជាច្រើនទៀត ដែលសុទ្ធសឹងជាសម្បត្តិវប្បធម៌ដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ។

ខ្មែរក្រោមមានទំនៀមទម្លាប់ ប្រពៃណីជាតិ ដ៏ល្អផូរផង់ ជាច្រើន តែនៅសេសសល់ និងលេចធ្លោជាងគេសព្វថ្ងៃនេះ គឺសិល្បៈល្ខោនបាសាក់ និងប្រពៃណីប្រណាំងទូក ឯប្រពៃណីដទៃទៀត ដូចជាពិធីរៀបអាពាហ៍ពិពាហ៍ជាដើម បានក្លាយតាមបែបយួនខ្លះ ៗ ទៅហើយ ។

រស់ក្រោមគំនាបអាណានិគមយួន ខ្មែរក្រោមបានបាត់បង់នូវប្រពៃណីទំនៀមទំលាប់ ហើយទីស្ថានប្រវត្តិសាស្ត្រនានាត្រូវខូចខាតស្ទើររលាយអស់ពីមាតុភូមិ ។ យួនតែងរិះរកគ្រប់មធ្យោបាយដើម្បីរំលាយវប្បធម៌ ប្រពៃណីខ្មែរ ធ្វើឲ្យព្រលឹងជាតិខ្មែរត្រូវបាត់បង់ទាំងមនុស្សជាតិ និងធនធានធម្មជាតិ តាំងពីដើមរហូតមកដល់សព្វថ្ងៃជាក់ស្តែង ដូចជាក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រោមពីសំណាក់យួនយៀកមិញ ដែលមានជនហ៊ូជីមិញជាមេក្លោង បានធ្វើឲ្យសហគមន៍ខ្មែរក្រោមយ៉ាងតិចចំនួន ២២ សហគមន៍ មាន ២២,០០០ គ្រួសារ និងមនុស្សចំនួន ១៩២,០០០ នាក់ ត្រូវរលាយសាបសូន្យទូទាំងកម្ពុជាក្រោម ។

អន្តរកាលជាបន្តបន្ទាប់មកទៀត យួនតែងប្រើគ្រប់មធ្យោបាយដើម្បីរំលាយពូជសាសន៍ខ្មែរ ។ ពេលនេះយួន បានប្តូរយុទ្ធសាស្ត្រពីការកាប់សម្លាប់ដោយផ្ទាល់ទៅជាការដាក់គំនាបលើវិស័យសេដ្ឋកិច្ច ភាសា អក្សរសាស្ត្រ និងទំនៀមទម្លាប់ប្រពៃណី ។

ដូច្នេះហើយ បានជាពេលនេះ គេឃើញយួនខំប្រឹងកែទម្រង់សិល្បៈល្ខោនបាសាក់ខ្មែរក្រោម ដោយបានដាក់បញ្ចូលនូវបទភ្លេងសំលៀកបំពាក់ និងក្បាច់រាំ ឲ្យផ្តេកផ្តួលទៅតាមរបៀប "កាយលឿង" យួនវិញ ។

ចំណែកប្រពៃណីប្រណាំងទូកទៀតសោត យួនបានកាឡៃ ដោយឆ្នាំខ្លះ យួនអនុញ្ញាតឲ្យខ្មែរក្រោមអុំតែមួយកន្លែងទូទាំងកម្ពុជាក្រោម ឆ្នាំខ្លះយួនបានហាមប្រាមមិនឲ្យខ្មែរក្រោមប្រមូលផ្តុំឡើយ ។

ជាក់ស្តែងក្នុងឆ្នាំ ២០០៤ កន្លងទៅនេះ យួនបានតម្រូវឲ្យខ្មែរក្រោមប្រារព្ធពិធីបុណ្យអុំទូកតាមខេត្តរៀង ៗ ខ្លួន ។ រីឯទូកងនៅស្រុកកន្លង់ ខេត្តព្រះត្រពាំង ឆ្នាំ ២០០៤ នេះ យួនមិនឲ្យខ្មែរគ្រប់គ្រង និងមិនឲ្យខ្មែរស្រុកកន្លង់ធ្វើជាកីឡាករចំណុះទូកនេះឡើយ យួនបែរជាទៅជួលខ្មែរនៅខេត្តឃ្លាំងមកធ្វើជាចំណុះទូកវិញ ឯជនជាតិយួនដែលមិនចេះវិធីសាស្ត្រលេងទូកងសោះ បែរជាអង្គុយក្បាលទូកស្រែកហៃអើ ! តាមតែចង្វាក់ខ្មែរអុំ បើមើលកាយវិការពីចម្ងាយគេឃើញជនជាតិយួនអង្គុយក្បាលទូកនោះ ហាក់ដូចជាប៉ិនប៉ៅទូកល្អណាស់ ព្រោះទូកនេះបានជាប់ចំណាត់ថ្នាក់លេខ ១ ក្នុងចំនោមទូកទាំង ៨ របស់ខេត្ត ។ ហើយនេះជាជំហានទីមួយ ដែលយួននឹងឈានដល់ការដណ្តើមយកប្រពៃណីប្រណាំងទូកនេះ ថាជារបស់យួននៅពេលខាងមុខ ។

ចំពោះបញ្ហា ដែលយួនបម្រុងអភិវឌ្ឍមណ្ឌលរមណីយដ្ឋានស្រះគូ ឲ្យទៅជាសួនពាណិជ្ជកម្មទេសចរណ៍នោះ គោលគំនិតរបស់យួនគ្មានអ្វីក្រៅពីចង់បំផ្លាញបរិស្ថាន បង្កឲ្យមានភាពអួរអ័ព្ទ និងឈានទៅលុបបំបាត់ដានប្រវត្តិសាស្ត្រខ្មែរក្រោមនោះឡើយ ៕

VOKK

# ឆ្មាំព្រំដែនយួនបិទមិនឱ្យព្រះសង្ឃ និង ពុទ្ធបរិស័ទខ្មែរនៅភ្នំពេញនាំបរិក្ខារកឋិនមកកម្ពុជាក្រោម

យោងតាមពាក្យបណ្ដឹងរបស់ជនរងគ្រោះ និងកំណត់ហេតុរបស់ឆ្មាំព្រំដែនយួនច្រកទ្វារក្អមសំណ ស្ថិតនៅក្នុងស្រុកកោះធំ ខេត្តកណ្ដាល ជាប់នឹងខេត្តមាត់ជ្រូក បានឲ្យដឹងថាកាលពីថ្ងៃទី០៣ វិច្ឆិកា ឆ្នាំ ២០០៤ កន្លងទៅនេះ ឆ្មាំព្រំដែនយួន បានរារាំងបិទផ្លូវមិនឲ្យភិក្ខុមួយអង្គ មានដើមកំណើតនៅកម្ពុជាក្រោម សព្វថ្ងៃគង់នៅរាជធានីភ្នំពេញ ឆ្លងដែនចូលទៅកាន់ស្រុកកំណើតនៅឯកម្ពុជាក្រោមឡើយ ។

ឆ្មាំព្រំដែនយួនមិនត្រឹមតែបិទផ្លូវព្រះអង្គ មិនឲ្យចូលស្រុកប៉ុណ្ណោះទេ ថែមទាំងបានបញ្ចេញអាកប្បកិរិយា ប្រើពាក្យសំដីមាក់ងាយដល់ព្រះសង្ឃពុទ្ធសាសនាខ្មែរ ព្រមទាំងបានរើកកាយសម្ភារៈជាប់តាមព្រះកាយរបស់ព្រះអង្គ រួចបានដកហូតយកសម្ភារៈ និងគ្រឿងបរិក្ខារកឋិនរបស់ព្រះអង្គថែមទៀតផង ។

សម្ភារៈ និងគ្រឿងបរិក្ខារកឋិនរបស់អង្គ ដែលត្រូវឆ្មាំព្រំដែនយួនដកហូតយករួមមាន ៖

១-សៀវភៅព្រះធម៌សត្តវិត្ត ១ ក្បាល

២-សៀវភៅមហាសង្ក្រាន្តឆ្នាំ ២០០៤ ១ ក្បាល

៣-រូបចម្លាក់ព្រហ្មមុខបួនធ្វើអំពីឈើ ១

៤-ព្រះឆាយាល័ក្ខណ៍សម្ដេចសង្ឃ ជួន ណាត ១ សន្លឹក

៥-ម៉ាស៊ីនថតរូប ១ គ្រឿង និងត្រៃចីវរ ១ ត្រៃ ។

សូមបញ្ជាក់ថា ៖ សម្ភារៈ និងគ្រឿងបរិក្ខារទាំងនេះ គឺព្រះសង្ឃ និងពុទ្ធបរិស័ទខ្មែរ នៅរាជធានីភ្នំពេញបានមូលមតិគ្នាជាឯកច្ឆ័ន្ទផ្ដើមធ្វើជាអង្គកឋិនទានមួយ ដើម្បីនាំយកទៅវេរប្រគេនដល់ភិក្ខុសង្ឃដែលគង់ចាំព្រះវស្សាអស់ត្រីមាសនៅឯវត្តមួយ ក្នុងខេត្តឃ្លាំង ដែនដីកម្ពុជាក្រោម ។

ជារឿយ ៗ ក្នុងឆ្នាំ ២០០៤ នេះ ការសុំទិដ្ឋាការឆ្លងដែនមកកម្ពុជាក្រោមរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទមានដើមកំណើតខ្មែរកម្ពុជាក្រោម ត្រូវបានស្ថានទូតយួនប្រចាំនៅទីក្រុងភ្នំពេញបដិសេធជានិច្ច ។

តាមថេរដីការបស់ព្រះសង្ឃរងគ្រោះ បានឲ្យដឹងថា បន្ទាប់ពីឆ្មាំព្រំដែនយួនរារាំងមិនឲ្យចូលស្រុកនោះ ព្រះអង្គបានវិលត្រឡប់មកភ្នំពេញវិញ ហើយបានចូលប្ដឹងស្ថានទូតយួននៅភ្នំពេញ ដោយផ្ទាល់អំពីបញ្ហានេះ ហើយត្រូវសមត្ថកិច្ចស្ថានទូតយួនបានស្ដីបន្ទោសព្រះអង្គថា ៖ "រឿងដែលឆ្មាំព្រំដែនបិទផ្លូវព្រះអង្គមិនឲ្យចូលស្រុកនោះក៏ព្រោះតែគ្រឿងបរិក្ខាររបស់ព្រះអង្គមានលាយឡំនឹងសៀវភៅធម៌អាថ៌ ក្បួនខ្នាតនៅក្នុងនោះ ដែលវាផ្ទុយពីគោលការណ៍ច្បាប់នៃប្រទេសវៀតណាម ។ ឯសម្ភារៈ និងគ្រឿងបរិក្ខាររបស់ព្រះអង្គ ដែលឆ្មាំព្រំដែនដកហូតយកនោះខាងស្ថានទូតមិនដឹងទេ សូមព្រះអង្គទៅដោះស្រាយនឹងឆ្មាំព្រំដែននោះចុះ" ។

ក្នុងនាមជាជនរងគ្រោះ និង ក្នុងនាមព្រះសង្ឃខ្មែរក្រោម ព្រះអង្គមានថេរដីកាអំពាវនាវសុំការធ្វើអន្តរាគមន៍ដូច្នេះ "អាត្មាសូមអំពាវនាវដល់អង្គការក្រៅរដ្ឋាភិបាលនានា និងសហព័ន្ធខ្មែរកម្ពុជាក្រោម មេត្តាជួយរកយុត្តិធម៌ឲ្យអាត្មាភាពផង កុំឲ្យគេរំលោភសិទ្ធិអាត្មាតទៅទៀត" ៕

VOKK

# ពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ នៅខេត្តព្រះត្រពាំង

ល្បែងប្រណាំងទូកងជាប្រពៃណីខ្មែរ ដែលមានមកតាំងពីយូរលង់ណាស់មកហើយ ។ ពិធីប្រណាំងនោះ មុននឹងឈានដល់ថ្ងៃប្រណាំង ដែលបានកំណត់យកថ្ងៃ ១៤ កើត, ថ្ងៃពេញបូរមី និងថ្ងៃ ១ រោច ខែកត្តិក ជាទិវាបុណ្យជាតិ "អុំទូក អកអំបុក សំពះព្រះខែ និងលយប្រទីប" នោះ តាមទំនៀមទម្លាប់ខ្មែរ គឺមុនពេលដល់ពិធីបុណ្យនេះ យ៉ាងយូរមួយខែ ឬ យ៉ាងឆាប់កន្លះខែ ក្រុមអ្នកលេងទូកតែងប្រារព្ធពិធីបួងសួងសែនព្រេនតាមគន្លងខ្មែរពីបុរាណ ដើម្បីរំកិលទូកចុះពីបង្គង ធ្វើការហាត់សមកម្លាំងកីឡាករ ។ តែអាជ្ញាធរយួន ឃុំគងបុណ្យ (យួនហៅងូវឡាក) ស្រុកទេសាសោម (យួនហៅកូវង៉ាង) ខេត្តព្រះត្រពាំង បានហាមប្រាមខ្មែរនៅឃុំគងបុណ្យនេះ មិនឲ្យប្រារព្ធពិធីរំកិលទូកចុះពីបង្គងតាមទំនៀមខ្មែរបុរាណឡើយ ។ យួនឲ្យខ្មែរ



សែងទូកចុះពីបង្គងជារបៀបធម្មតា និងឲ្យហ្វឹកហាត់សមកំលាំងកីឡាករមុនការប្រកួតតែបីថ្ងៃប៉ុណ្ណោះ ។

ចំណែកទូកងស្រុកកន្លង់ (យួនហៅកាងឡុង) ខេត្តព្រះត្រពាំង វិញ គឺយួនមិនឲ្យខ្មែរនៅស្រុកនេះគ្រប់គ្រងទូក និងយកទូកនេះទៅប្រារព្ធពិធីអុំទូកឡើយ គឺអាជ្ញាធរស្រុកកន្លង់ ឲ្យយួនជាអ្នកគ្រប់គ្រង ហើយបានទៅជួលកីឡាករខ្មែរមកពីខេត្តឃ្លាំង ធ្វើជាចំណុះទូក ដោយដាក់អ្នកអង្គុយក្បាលទូកជាជនជាតិយួន ។

ពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ ឆ្នាំនេះប្រារព្ធធ្វើនៅបរិវេណរមណីយដ្ឋានស្រះគូ ខេត្តព្រះត្រពាំង ។

ការប្រណាំងទូក បានប្រព្រឹត្តទៅអស់រយៈពេល ១ ថ្ងៃ ជាលទ្ធផលក្នុងចំណោមទូកទាំង ៤ គូ ក្នុងខេត្តព្រះត្រពាំង ទូកដែលជាប់ចំណាត់ថ្នាក់លេខ ១ ហើយបានទទួលប្រាក់រង្វាន់ ១៥ លានដុងពីស្ថាប័នវប្បធម៌ខេត្ត គឺទូកស្រុកកន្លង់ ។

ពិធីបុណ្យក្នុងឆ្នាំនេះ មានពុទ្ធបរិស័ទ ព្រះសង្ឃខ្មែរ និងមានការចូលរួមពីស្ថាប័នវប្បធម៌ខេត្តព្រះត្រពាំងផងនោះ បានរៀបចំអង្គពិធី មានជាអាទិ៍ដូចជា ៖ ពិធីប្រណាំងទូក ពិធីអកអំបុក សំពះព្រះខែ លយប្រទីប បង្ហោះគោម ព្រមទាំងមានការប្រគុំតន្ត្រីសម័យបុរាណ ល្បែងប្រជាប្រិយ របាំ និងមានការសម្ដែងល្ខោនបាសាក់ ដោយបានបង្ហាញពីសំលៀកបំពាក់ខ្មែរក្នុងសម័យកាលនីមួយ ៗ និងមានរៀបចំការតែងទិសដែលចាត់តាំងឡើង ដោយពុទ្ធបរិស័ទចំណុះជើងវត្ត ។ ទិសនីមួយ ៗ បានរៀបចំតុបតែងជារចនាបទខ្មែរយ៉ាងល្អប្រណិត ។ ក្នុងនោះមានការដាក់តាំងវត្ថុបុរាណ ដែលជាកេតនភ័ណ្ឌជាតិខ្មែរដ៏មានតម្លៃ និងផលិតផលជាច្រើនទៀត ដែលសុទ្ធសឹងជាសមិទ្ធផលរបស់ខ្មែរសម័យនេះ ។

គេសង្កេតឃើញមានប្រជារាស្ត្រខ្មែរ និងមានយួន ចិន ផងដែរ បានមកចូលរួមអបអរសាទរក្នុងពិធីបុណ្យយ៉ាងច្រើនកុះករ ។ ស្ថាប័នវប្បធម៌ខេត្ត ក៏បានជូនជារង្វាន់ដល់ការតែងទិស ចំពោះទិសដែលល្អប្រណិតតាមបែបខ្មែរ នឹងទទួលបានរង្វាន់ ៤ លានដុង ។ តាមការសំភីមើលរបស់អ្នកចូលរួម គឺឃើញយួនគ្មានខ្វះខ្នែងអ្វីក្រៅពីការថតរូប ថតវីដេអូ ដែលការថតនេះគ្រាន់តែជាល្បិចថ្លឹនភ្នែកបោកប្រាស់មតិអន្តរជាតិប៉ុណ្ណោះ ៕

VOKK

# រមណីយដ្ឋានជាតិស្រះគូ កំពុងរងការគំរាមកំហែង

ស្រះស្រី ឬ ស្រះគូ ជារមណីយដ្ឋានប្រវត្តិសាស្ត្រដ៏ចំណាស់មួយរបស់ខ្មែរ ។ រមណីយដ្ឋាននេះស្ថិតក្នុងឃុំថ្មដាច់ (យួនហៅលឿងហ្វា) ស្រុកស្រះគូ (យួនហៅចូវថាញ់) ខេត្តព្រះត្រពាំង ។

ស្រះគូស្ថិតនៅប៉ែកខាងលិច ចម្ងាយប្រមាណ ៥ គីឡូម៉ែត្រពីទីរួមខេត្ត ។ តាមរឿងព្រេងដំណាលត ៗ មកថា ស្រះនេះកើតឡើងដោយការប្រកួតប្រជែងជីកស្រះរវាងបុរស និងស្ត្រី ដែលបានដាក់ខសន្យានឹងគ្នាថា បើភាគីស្រីចាញ់ ស្រីត្រូវតែបន្តការចូលស្ដីដណ្ដឹងប្រុសតាមទំនៀមពីបុរាណ តែបើភាគីប្រុសចាញ់ ទំនៀមស្រីដណ្ដឹងប្រុសនឹងត្រូវលុបចោល គឺខាងប្រុសត្រូវតែចូលស្ដីដណ្ដឹងស្រីវិញ ។ លទ្ធផលនៃការប្រកួត គឺខាងប្រុស ៗ បានជីកស្រះចាញ់ស្រី ៗ ។

សព្វថ្ងៃ ស្រះគូមានទំហំប្រមាណ ១ គីឡូម៉ែត្របួនជ្រុង នៅជុំវិញភ្លឺស្រះគេឃើញដើមគគីរធំ ៗ ខ្ពស់សន្លឹម ឡើងគល់ចាក់ឫសជ្រោងខ្ពស់ ហួសក្បាលមនុស្ស ។ ជារៀងរាល់រដូវវស្សា ពេលភ្លៀងធ្លាក់ម្ដង ៗ ទឹកបានហូរច្រោះដីភ្លឺស្រះធ្លាក់ចុះទៅក្នុងស្រះ ធ្វើឲ្យដើមគគីរឡើងគល់ និងលេចឫសគ្រប់ ៗ ដើម ។ នៅប៉ែកខាងត្បូងនៃស្រះ មានវត្តមួយដែលជាកេតនភ័ណ្ឌជាតិខ្មែរ គឺវត្តអង្គររាជបូរី វត្តនេះ បានកសាងឡើងក្នុងគ.ស. ៩៩០ ។

ជារៀងរាល់ថ្ងៃ មានភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិឥតដាច់បានមកទស្សនា និងកំសាន្តនៅរមណីយដ្ឋានស្រះគូ ដ៏ប្រណីតនេះ មិនចាញ់រមណីយដ្ឋានប្រវត្តិសាស្ត្រខ្មែរមួយទៀត គឺភ្នំឆ្ងាម ខេត្តមាត់ជ្រូកនោះឡើយ ។ អាស្រ័យលើវិស័យទេសចរណ៍ ជាមូលដ្ឋានធ្វើឲ្យវត្តអង្គ និងស្ថាប័នវប្បធម៌ខេត្តព្រះត្រពាំង បានទទួលផលកម្រៃច្រើនគួរសមសម្រាប់ពង្រឹងវប្បធម៌ជាតិ ។

កាលពីចុងឆ្នាំ ២០០៤ ក្រសួងទេសចរណ៍ រួមនឹងអាជ្ញាធរមូលដ្ឋានយួន បានមកលួងលោមព្រះចៅអធិការ និងពុទ្ធបរិស័ទចំណុះជើងវត្តអង្គររាជបូរី ដើម្បីសុំទិញមណ្ឌលស្រះគូ ក្នុងតម្លៃមួយកោដិដុល្លារអាមេរិក តែព្រះសង្ឃ និងពុទ្ធបរិស័ទបានប្ដេជ្ញាថា ទោះជាតម្លៃថ្លៃកប់ពពកយ៉ាងណាក៏ដោយ ក៏មិនលក់ ឬ ប្រគល់សិទ្ធិផ្ដាច់មុខគ្រប់គ្រងសម្បត្តិជាតិនេះទៅឲ្យយួនជាដាច់ខាត ។

យួនចង់បានស្រះគូនេះ ក្នុងគម្រោងរៀបចំជាសួនពាណិជ្ជកម្មទេសចរណ៍ ។ គេនឹងសាងសង់អាគារពាណិជ្ជកម្មធំៗ ភោជនីយដ្ឋាន និងក្លឹបកំសាន្ត នៅជុំវិញមណ្ឌលស្រះ ឯនៅក្នុងស្រះ គេនឹងរៀបចំជាសួនមច្ឆាទៀតផង ។

តាមមតិរបស់ព្រះសង្ឃ និងពុទ្ធបរិស័ទ បានឲ្យដឹងថា គេធ្វើបែបនេះមិនមែនជាបែបផែនលំអ ឬ អភិវឌ្ឍស្រះគូនោះទេ តែវាជាការបំពុលបរិស្ថាន ហើយសន្សឹម ៗ រមណីយដ្ឋានជាតិខ្មែរនេះ នឹងត្រូវវិនាសមិនខានឡើយ ៕ VOKK

ទិដ្ឋភាពរមណីយដ្ឋានស្រះគូ ឬ ស្រះស្រី ខេត្តព្រះត្រពាំង



# លិខិតអំពាវនាវរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម

សូមគោរពចូលមក

-អង្គការសុខភាពពិភពលោក
-ឯកឧត្តម Kofi Annan អគ្គលេខាធិការអង្គការសហប្រជាជាតិ
-ឯកឧត្តម George W. Bush ប្រធានាធិបតីសហរដ្ឋអាមេរិក
-ឯកឧត្តម John Nomrod នាយកអង្គការយូអ៊ីនភីអូ និង សមាជិក-សមាជិកាទាំងអស់
-លោកប្រធានាធិបតីកិត្តិយស និង លោកនាយករដ្ឋមន្ត្រីនៃប្រទេសកូសាវ៉ូ
-លោកប្រធានាធិបតីកិត្តិយស និងលោកនាយករដ្ឋមន្ត្រីនៃប្រទេសទីម័រខាងកើត
-សមាជិក-សមាជិកាកិត្តិយសសភា និង សភាតំណាងរាស្ត្រទាំងអស់នៃបណ្ដាប្រជាជាតិ ជុំវិញពិភពលោក
-សមាជិក-សមាជិកានៃអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ទទួលបន្ទុកសិទ្ធិមនុស្ស និងសេរីភាពសាសនា

អស់លោក លោកស្រីជាទីគោរព !

យើងខ្ញុំ ជាប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម សូមជម្រាប ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីគោរព ឲ្យបានជ្រាប ថា យើងខ្ញុំសរសេរលិខិតនេះ មានបំណងស្វែងរកនូវកិច្ចគាំពារ និង ជំនួយឧបត្ថម្ភពីឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដើម្បី ជួយជម្រុញឲ្យសាធារណរដ្ឋសង្គមនិយមវៀតណាម អនុវត្តច្បាប់ អន្តរជាតិ ។ បក្សកុម្មុយនិស្តវៀតណាម ចេះតែបន្តនូវការរំលោភ បំពានសិទ្ធិមនុស្ស និងជំនឿសាសនា ប្រឆាំងនឹងខ្មែរកម្ពុជាក្រោម នៅក្នុងប្រទេសវៀតណាមជាហូរហែមិនឈប់ឈរឡើយ ។

ទឹកដីខ្មែរកម្ពុជាក្រោម មានផ្ទៃក្រឡាចំនួន ៦៨,៦០០ គីឡូ-ម៉ែត្រការេ ដែលជាដែនដីសណ្ដទន្លេមេគង្គ ស្ថិតនៅភូមិភាគខាងត្បូង នៃប្រទេសវៀតណាមនោះ ត្រូវរដ្ឋាភិបាលអាណានិគមនិយមបារាំង ប្រគល់សិទ្ធិត្រួតត្រាទៅឲ្យយួន កាលពីថ្ងៃទី ០៤ មិថុនា ១៩៤៩ ដោយប្រជារាស្ត្រខ្មែរក្រោមជាម្ចាស់ទឹកដីមិនបានដឹងឮសោះឡើយ ។ ខ្មែរកម្ពុជាក្រោម ជាប្រជាជាតិដើម ដែលបានរស់នៅលើដែនដីសណ្ដ ទន្លេមេគង្គ ចាប់តាំងពីសតវត្សរ៍ទី ១ មកម្ល៉េះ មិនត្រឹមតែប៉ុណ្ណោះ ខ្មែរកម្ពុជាក្រោមនៅមានវប្បធម៌-អរិយធម៌របស់ខ្លួន ដ៏ល្អប្រពៃ ដូចជា ក្រិត្យក្រមសីលធម៌ ភាសា និងអក្សរសាស្ត្រ ជាដើម ដែលមាន លក្ខណៈខុសគ្នាស្រឡះពីជាតិសាសន៍វៀតណាម ។

សាធារណរដ្ឋសង្គមនិយមវៀតណាម ចេះតែបន្តសកម្មភាព សង្កត់សង្កិនមកលើជនជាតិភាគតិច ក្នុងប្រទេសវៀតណាមជាហូរហែ មិនលស់ពេលឡើយ ។ ជាសក្ខីភាព ដូចជាជនជាតិភាគតិចម៉ុង-តាញ៉ា ស្ថិតក្នុងតំបន់ខ្ពង់រាបកណ្ដាលនៃប្រទេសវៀតណាម សព្វថ្ងៃ នេះ ពួកគេកំពុងប្រឈមមុខនឹងការបង្ក្រាបយ៉ាងខ្លាំងក្លា ពីសំណាក់ រដ្ឋាភិបាលវៀតណាម ហើយប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមនៅដែនដី សណ្ដទន្លេមេគង្គ ក៏ស្ថិតក្នុងស្ថានភាពដូចគ្នានេះដែរ ។

ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម សូមអំពាវនាវដល់បណ្ដារដ្ឋា ភិបាល និងអង្គការអន្តរជាតិនានាលើលោក សុំឲ្យមានការជួយទប់ ស្កាត់នូវរាល់អំពើឃោរឃៅព្រៃផ្សៃទាំងឡាយ ដែលបាន និងកំពុងបង្ក ឡើងដោយអាណានិគមយួនមកលើប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមគ្រប់ សម័យកាល ។ ចំណែកប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមវិញ តែងមាន គំនិតចងមេត្រីភាព គោរពស្រឡាញ់រាប់អាន មានការយោគយល់ អធ្យាស្រ័យចំពោះគ្នា ជឿទុកចិត្តគ្នាដោយស្មោះស ចេះការពារផល ប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ហើយតែងរកយុត្តិធម៌ឲ្យគ្នាតាមខ្នាត អន្តរជាតិជានិច្ច ។

ដើម្បីជាភ័ស្តុតាងបង្ហាញដល់អស់លោក លោកស្រីឲ្យបាន ជ្រាបពីទង្វើដ៏ព្រៃផ្សៃរបស់វៀតណាម មកលើបងប្អូនខ្មែរក្រោមនោះ យើងខ្ញុំសូមលើកយកនូវរបាយការណ៍មួយ ដែលរាយការណ៍ដោយ កាសែតក្នុងស្រុកមួយ កាលពីថ្ងៃសុក្រ ទី ២៤ មករា ឆ្នាំ ២០០៣ ក្នុងខេត្តពលលាវ ថា មានជំងឺដ៏ចម្លែក ១ ជាច្រើនប្រភេទ បាននិង កំពុងយាយីដល់អាយុជីវិតប្រជាជនខ្មែរក្រោមក្នុងឃុំអ្នកស្រែ ហើយ នឹងរាលដាលទៅដល់បណ្ដាស្រុកភូមិដទៃទៀត ដូចជាស្រុកវិញចូវ ជាដើម ។ មានប្រជាជនខ្មែរកម្ពុជាក្រោមប្រមាណ ៣០០០ នាក់ បាន កើតជំងឺនេះ ។ ឥទ្ធិពលនៃជម្ងឺបានធ្វើឲ្យអ្នកខ្លះខ្វាក់ភ្នែកម្ខាង គឺខាង ស្ដាំ ឬ ឆ្វេង ហើយអ្នកខ្លះទៀតត្រូវខ្វាក់ទាំងសង្ខាងតែម្ដង ។ រោគ សញ្ញានៃជំងឺនោះ បានបង្ហាញចេញមក ដូចខាងក្រោមនេះ ៖

ភ្នែកឡើងក្ដៅ ទឹកភ្នែកហៀរ ឈឺត្របកភ្នែក ភ្នែកឡើងខ្ចុះ ជំងឺរួញកែវភ្នែក ទីបំផុតត្រូវខូចកែវភ្នែកតែម្ដង ។ល។ គ្មានប្រភពណា មួយបញ្ជាក់ឲ្យដឹងថា ជនរងគ្រោះទាំងនោះបានទទួលការព្យាបាល យ៉ាងណាខ្លះ ទើបបណ្ដាលឲ្យមានជំងឺដ៏ចំលែកបែបនេះកើតឡើង ឡើយ ។ យោងតាមសេចក្ដីរាយការណ៍មួយបានឲ្យដឹងថា ជំងឺខ្វាក់ ភ្នែកចំនួន ៩៨,៧ % បណ្ដាលមកពីការប្រើប្រាស់ទឹកមិនស្អាត គ្មាន អនាម័យក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដោយហេតុតែពួកគេមិនបាន យល់ដឹងពីឥទ្ធិពលនៃថ្នាំពុល ដូចជាថ្នាំសម្លាប់សត្វល្អិត ថ្នាំបាញ់មិន ឲ្យស្មៅដុះ និងការប្រើប្រាស់ជីគីមីច្រើនប្រភេទទៀត ដែលរដ្ឋាភិបាល វៀតណាមអនុញ្ញាតឲ្យប្រើក្នុងវិស័យកសិកម្ម ។

ឥឡូវ ជំងឺនេះបានរាលដាលសាយភាយទូទាំងខេត្តឃ្លាំង ហើយ ដូចជាស្រុកមីទូ មីស្មៀង ជាដើម ហើយនឹងរាលដាលដល់ ខេត្តព្រះត្រពាំងថែមទៀត ។ ជម្ងឺខ្វាក់ភ្នែកនេះ ត្រូវការការព្យាបាល

តាមវេជ្ជសាស្ត្រជាបន្ទាន់ ហើយត្រូវស្រាវជ្រាវរាវរកឲ្យឃើញនូវបុព្វហេតុដែលបានបង្កឲ្យមានជំងឺនេះកើតឡើង ។ ការស្រាវជ្រាវនេះ ជាត្រីវិស័យដ៏សំខាន់សម្រាប់ចង្អុលបង្ហាញ និងបកអាក្រាតពីកលល្បិច និងអំពើដ៏ពិសពុលរបស់អាណានិគមយួនមកលើខ្មែរកម្ពុជាក្រោម ។ អាណានិគមយួន នៅតែបន្តនូវការចងកម្មពៀរ និងធ្វើបាបប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមរហូត ដោយមិនបានរិះរកមធ្យោបាយទប់ស្កាត់ ឬ ខ្វល់ខ្វាយព្យាបាលពួកគេឡើយ ហើយទុកឲ្យពួកគេខ្វាក់ភ្នែកទាំងក្ដីឈឺចាប់ ។

របាយការណ៍ដដែលនេះ បានបញ្ជាក់បន្ថែមទៀតថាគ្រួសារមួយដែលមានសមាជិកប្រាំមួយនាក់ ក្នុងនោះមានបួននាក់ទៅហើយដែលបានរងគ្រោះដោយជំងឺខ្វាក់ភ្នែកនេះ ។ ក្នុងគ្រួសារ ប្ដីទទួលបន្ទុករកប្រាក់ចិញ្ចឹមគ្រួសារ ប៉ុន្ដែពេលនេះស្ទើរតែគ្រប់គ្រួសារទាំងអស់ បុរសជាប្ដីគ្មានលទ្ធភាពនឹងរកប្រាក់ចំណូលសម្រាប់គ្រួសារបានទៀតទេ ។ ដូចពាក្យចាស់លោកបានពោលថា «បាតុភូតនឹងកើតមានឡើងដល់ពួកយើងម្ដងទៀត គ្រួសារពួកយើងប្រាកដជានឹងត្រូវវិនាស ហើយកូនចៅជំនាន់ក្រោយរបស់យើងនឹងគ្មានអនាគតទេ» ។ ប្រជាជនខ្មែរកម្ពុជាក្រោម ចង់មានកម្រិតជីវភាពមួយសមរម្យ និងរស់នៅ ដោយខ្លួនជាអ្នកសម្រេចនូវជោគវាសនារបស់ខ្លួនផ្ទាល់ ។

លើសពីនេះទៅទៀត នៅពេលដែលមានជំងឺគ្រុនផ្ដាសាយបក្សី ទៅយាយីអាយុជីវិតប្រជាជនវៀតណាមមួយចំនួនតូចនោះ បានបង្ហាញយ៉ាងច្បាស់ថា របបគណបក្សកុម្មុយនិស្តវៀតណាម គ្មានមេត្តាធម៌ទាល់តែសោះចំពោះខ្មែរក្រោម ។ ជំងឺនេះគ្រាន់តែធ្វើឲ្យប្រជាជនវៀតណាមរងគ្រោះក្នុងចំនួនតិចតួចសោះ រដ្ឋាភិបាលវៀតណាមស្រែកក្ដែង ៗ រង្គើទឹក រង្គើដី សុំឲ្យអង្គការសុខភាពពិភពលោក ( WHO ) ជួយធ្វើអន្តរាគមន៍ដើម្បីស្វែងរកជំនួយជាបន្ទាន់ ប៉ុន្តែចំណែកខាងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមមានប្រមាណ ៣០០០ នាក់ដែលកំពុងរងគ្រោះដោយជម្ងឺខ្វាក់ភ្នែកនោះ ជាចំនួនធំក្រៃលែង បើធៀបនឹងជនជាតិវៀតណាម ដែលបានរងគ្រោះដោយជំងឺផ្ដាសាយបក្សីនោះ ។ រដ្ឋាភិបាលវៀតណាមមិនបានឈឺឆ្អាល និងយកចិត្តទុកដាក់ក្នុងការជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលកំពុងរងគ្រោះនោះទាល់តែសោះ ថែមទាំងធ្វើព្រងើយកន្តើយ និងត្រេកអរចំពោះជំងឺដ៏ចម្លែកនេះទៅវិញ ។

យើងខ្ញុំជាប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម សូមថ្កោលទោសចំពោះអំពើរំលោភបំពានដោយហឹង្សាទាំងឡាយ ដែលរដ្ឋាភិបាលវៀតណាមបានបង្កឡើង ហើយសូមឲ្យសំឡេងរបស់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមលាន់ឮទៅដល់ពិភពលោក ជាពិសេសរដ្ឋាភិបាលសហរដ្ឋអាមេរិក និងអង្គការសុខភាពពិភពលោក ជួយពិចារណានូវអំពើដ៏កំណាច និងរំលោភសិទ្ធិមនុស្សបែបនេះផងចុះ ។ យើងខ្ញុំជាប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមសរសេរលិខិតនេះ មានបំណងស្វែងរកនូវជំនួយពីបណ្ដារដ្ឋាភិបាល និងអង្គការមនុស្សធម៌លើលោក ជួយឧបត្ថម្ភនូវសម្ភារៈបរិក្ខារពេទ្យ វេជ្ជបណ្ឌិត និងថ្នាំសង្កូវជាដើម សម្រាប់ព្យាបាលជនរងគ្រោះដោយជម្ងឺខ្វាក់ភ្នែកទាំងនោះ ព្រោះរដ្ឋាភិបាលវៀតណាមបានព្យាយាមរារាំង មិនឲ្យប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមទទួលបានការព្យាបាលតាមក្បួនវេជ្ជសាស្ត្រត្រឹមត្រូវឡើយ ។ អំពើនេះជាការរំលោភបំពានសិទ្ធិមនុស្សយ៉ាងច្បាស់ក្រឡែត ដែលរដ្ឋាភិបាលវៀតណាម មិនអាចប្រកែកបានឡើយ ។

មិនតែប៉ុណ្ណោះ រដ្ឋាភិបាលវៀតណាមបានចាត់ទុកខ្មែរកម្ពុជាក្រោម ជាមនុស្សនៅក្រៅច្បាប់អន្តរជាតិ ។ អំពើព្រៃផ្សៃរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានធ្វើមកលើប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមទាំងប៉ុន្មានត្រូវបញ្ឈប់ជាបន្ទាន់ ហើយអនុញ្ញាតឲ្យប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលរងគ្រោះដោយជម្ងឺខ្វាក់ភ្នែកបានទៅព្យាបាលតាមវេជ្ជសាស្ត្រត្រឹមត្រូវ និងលទ្ធភាពរបស់ខ្លួនផង ។

ការឈឺចាប់ទាំងប៉ុន្មានក្នុងអតីតកាល បានសាបរលាបអស់ឥទ្ធិពលទៅហើយ តែសព្វថ្ងៃយួននៅតែបន្តការគំរាមកំហែងដល់អាយុជីវិតពូជសាសន៍ខ្មែរក្រោមទៀត ។ បំណងប្រាថ្នារបស់ខ្មែរក្រោម គឺសូមឲ្យវៀតណាមកែប្រែឥរិយាបទ និងឈប់បង្កនូវសេចក្ដីទុក្ខសោកទាំងឡាយមកលើប្រជាជនខ្មែរក្រោមតទៅទៀត ។ ជាការពិត ការរៀបចំគោលនយោបាយរវាងវៀតណាម និងខ្មែរក្រោម នាពេលបច្ចុប្បន្ននេះ គ្មានផលប្រយោជន៍អ្វីទាល់តែសោះ ចំពោះកូនចៅជំនាន់ក្រោយទាំងសង្ខាង ទាំងបច្ចុប្បន្ន និងទៅថ្ងៃអនាគត ។

សរុបមក យើងខ្ញុំជាប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម មានជំនឿជឿជាក់យ៉ាងមុតមាំថា មនុស្សជាតិ និងក្រុមអង្គការមនុស្សធម៌សប្បុរសធម៌នៅលើលោក ជាពិសេសរដ្ឋាភិបាលសហរដ្ឋអាមេរិកដែលមានតួនាទីថែរក្សាការពារអាយុជីវិតប្រជាជនរាប់លាននាក់ នៅជុំវិញពិភពលោក រួមទាំងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមផងនោះ នឹងជួយខ្មែរកម្ពុជាក្រោម ឲ្យរួចផុតពីអំពើដ៏កំណាចយង់ឃ្នងរបស់របបកុម្មុយនិស្តវៀតណាម ហើយនិងរៀបចំឲ្យខ្មែរកម្ពុជាក្រោមបានរស់នៅដោយសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង គ្រប់គ្រងជោគវាសនាខ្លួនក្នុងជីវិតសន្តិភាពយ៉ាងពិតប្រាកដ ។ម្យ៉ាងទៀត សូមឯកឧត្តមលោជំទាវ អស់លោក លោកស្រី ទាំងអស់ មេត្តាជួយគាំទ្រសេចក្ដីអំពាវនាវនេះ នោះបានសេចក្ដីថា អស់លោក លោកស្រី បានចូលរួមជួយថែរក្សាការពារអាយុជីវិតប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ឲ្យផុតពីអំពើព្យាបាទនានា របស់របបគណបក្សកុម្មុយនិស្តវៀតណាមដូច្នោះដែរ ៕

*សូមអស់លោក លោកស្រីទទួលការគោរពអំពីយើងខ្ញុំ*

*ថ្ងៃទី ១៧ ធ្នូ ២០០៤*



*ប្រជារាស្ត្រខ្មែរក្រោមដែលរងគ្រោះដោយជំងឺខ្វាក់ភ្នែក នៅកម្ពុជាក្រោម*

# រឿងកំពប់តែអុច

អត្ថបទកំណាព្យនេះ ត្រូវបានរក្សាទុកអក្ខរាវិរុទ្ធ
តាមច្បាប់ដើមទាំងស្រុង

## សាស្ត្រាវត្តក្រូច – រៀបរៀងដោយសាស្ត្រាចារ្យ ឃឹន សុខ

៩០-សឹងតែខ្មៅនព្រៃជាៗ មេបានទ្រព្យា
ហើយខំធ្វើការគ្រប់ខ្លួន។

៩១-លុះបានច្រើនជាសំនួន ហើយនាំទាំងខ្លួន
ទៅជូនលោកឲ្យស្គាល់ជាក់ ។

៩២-អព្ភៃត្បែសអរឲ្យស័ក្តិ ឲ្យមាសឲ្យប្រាក់
យសស័ក្តិសឹងតែជាធំ ។

៩៣-ហើយល្បៀងឲ្យស៊ីបន្សំ អស់មេធំ ៗ
អរឯងអស់បាត់ចេញទៅ ។

៩៤-មានមេវះវៃឯក្រៅ មិនបានចូលទៅ
ហេតុនៅពុំទាន់ជឿជាក់ ។

៩៥-ឃើញគ្នាបានឡើងបុណ្យស័ក្តិ
បានមាសបានប្រាក់ ប្រាកដប្រែកបថ្កើងក្រៃ។

៩៦-អស់មេវេះវេហក្នុងព្រៃ អរឯងទីទៃ
ចូលទៅទាំងអស់ឥតសល់ ។

៩៧-អព្ភៃត្បែសអរឥតដល់ ឲ្យអស់ពួកពល
លាងបាយឲ្យស៊ីផឹកផង ។

៩៨-ស្រវឹងពេកពន់កន្លង លោកឲ្យចាប់ចង
ចាក់កាប់សម្លាប់អស់ទៅ ។

៩៩-ស្រុកខ្មែរឥតឯមានសៅ ហ្មងមោះទោសទៅ
មករកស៊ីសុកសប្បាយ ។

១០០-អស់រាស្ត្ររកស៊ីសុះសាយ ចេញចូលជួញចាយ
ទៅជិតទៅឆ្ងាយសឹងបាន ។

១០១-ឥតចោរឃោរឃៅឈ្លានពាន ប្លមប្លន់រុករាន
ឲ្យមានមន្ទិលទោសទុក ។

១០២-សឹងស្ងួនស្ងាត់បាត់គ្រប់ស្រុក រាយរកស៊ីចុក
សឹងសុកសប្បាយក្សេមក្សាន្ត ។



១០៣-ទោះទ្រព្យភ្លេចចោលសព្វស្ថាន
ឥតអ្នកណាហ៊ាន និងបានរើសយកគ្មានសោះ ។

១០៤-ទោះទាំងកាំបិតបន្ទោះ ទ្រព្យតិចឡើយនោះ
ចោលចុះដោយដីឥតក្រែង ។

១០៥-ស្រុកខ្មែរសឹងតែនោះឯង ឥតអារម្មណ៍ក្រែង
ក្របីគោលែងចោលបាន ។

១០៦-សឹងសុខសប្បាយក្សេមក្សាន្ត
សព្វស្រុកសព្វស្ថាន ឥតមានមន្ទិលទោសា ។

១០៧-សកលមណ្ឌលភពភា ក្រុងកម្ពុជបុរីបុរាណ-
សាន្តសុខ ។

១០៨-រាស្ត្រផងចងជាទំនុក ច្រៀងលេងគ្រប់ស្រុក
ជាសុកសប្បាយគ្រប់គ្នា ។

១០៩-បទកាកគតិតែង តំណើរតំណែងទំនុកនោះថា
សរសើរត្បិទបុណ្យ គុណាគិតរក្សា
រាស្ត្ររេងសុក្ខា ឥតឯកំដើង ។

១១០-ផ្គលាន់ព្រៃណោន កាលរាជចៅហ្វាវបែន
ក្រមុំដប់មួយស្លឹង ខ្លះយកទទេ ឥតឯកុំដើង
មេម៉ាយកំព្រើង ១០ស្លាពុកមួយ ។

១១១-ស្រុកយើងសកល ឥតឯអំពល់
អំពើចាយ លោកចាប់ចោរឃ្មួល
អស់ឥតទុក្ខា ។
១១២-រាស្ត្រច្រៀងសរសើរ ទំនុកដំណើរ
តំណាលកាលគ្រា អង្គៃត្បែសបែន
គ្រងជាចៅហ្វារ រាស្ត្ររីងសុក្ខា ឥតឯអំពល់ ។
១១៣-ឯអង្គអង្គៃ ត្បែសបែននោះនៃ
នៅនឹកយុងយល់ថាអញពិតជា រក្សាសុកល
ភូមិភពមណ្ឌល ក្រុងកម្ពុជា ។
១១៤-ឥឡូវសុកសាន្ត ដូចដោយនូវក្នាន
គំនិតប្រាជ្ញា គួរគិតចូលទៅ
ព្រះចៅយុធ្យា ទូលតាមដោយនា
ដំណើរសេចក្តី ។
១១៥-គិតស្រេចពុំលង់ លោកប្រើប្រៀបប្រុង
ចងគ្រឿងដំរី បបូរស្រពូស្រេច
រំពេចឆាបខ្មី ទៅទេពបូរី
ដល់ដូចចិន្តា ។
១១៦-ដល់ហើយចូលទូល តាមដោយនៅបូរ
បូរីរម្យា បពិត្រក្រាបទូល ឥសូរសិរិសា
ក្រុងកម្ពុជា សុកសាន្តឥតហ្មង ។
១១៧-ព្រះចៅយុធ្យា បានជ្រាបប្រការ
ប្រាកដនោះហោង ទ្រង់ព្រះចិន្តា
ថាចៅជាច្បង អង្គច័ន្ទនោះហោង
ល្អមគ្រងសីមារ ។
១១៨-គិតស្រេចពុំយូរ មានព្រះបន្ទូល
និងលោកចៅហ្វារ អង្គៃត្បែសផង
នាំលូងលេលា មកគ្រងសេមារ
ឯស្រុកខ្មែរវិញ ។
១១៩-ហើយត្រាស់ប្រើពញា យោមរាជជាតិជា
សៀមសុតនោះមិញ ឲ្យរៀបទ័ពទឹក
ពន្លឹកចចេញ ជូនលូងមកវិញ
ដល់បាត់ដំបង ។
១២០-ឯអង្គៃត្បែស ពិតពុំប្រហែស
ប្រាមប្រាប់អ្នកផង ឲ្យសង់ដំណាក់
ទំនៀបផ្គូផ្គង ទទួលស្តេចហោង
ជិតជើងកំពង់ ។
១២១-ស្តេចដល់ចូលចាប់ បោះបង្គោលខ្ជាប់
ស្តេចឡើងទៅគង់ ជាសុខក្សេមក្សាន្ត
ទាំង៤ព្រះអង្គ អង្គៃត្បែសផ្គង់ គ្រប់អង្គទាំង៤ ។
១២២-ស្រេចហើយអង្គៃ ត្បែសយកកូនស្រី
បង្កើតនឹងខ្លួន ល្អណាស់ឥតអង្គ
ត្រចង់សមសួន កូនស្រីទាំង៤ រើសតាមទ័យា ។
១២៣-ឯលូងអង្គច័ន្ទ ព្រះទ័យគួចកាន់
នាងទេពធិតា អង្គកាយកណ្តាល
ត្រកាលនេត្រា ភ្លេយន៍ជ្រះថ្លារ
ភ័ក្ត្រាផូផង់ ។
១២៤-ស្តេចសព្វព្រះទ័យ នាងនោះណាស់នៃ
នឹកនឹងរួមអង្គ អង្គៃត្បែសយល់
កិច្ចកល់ពុំលង់ ថ្វាយតាមចំណង់ ព្រះរាជចិន្តា ។
១២៥-ហើយធ្វើសំបុត្រ ប្រាមប្រាបប្រាកដ
អស់រាស្ត្រប្រជា ឲ្យទាំងប្រាប់ផ្លូវ
ឲ្យត្រូវគ្រប់គ្នា ឲ្យរៀបពន្លា
ធ្វើជារហ័ស ។
១២៦-ពីបាត់ដំបង ពោធិសាត់ក្តីហោង
មកដល់ទាំងរាស្ត្រ ឲ្យខំប្រាលប្រាប់
ឲ្យរៀបរហ័ស ស្តេចបន្ទូលត្រាស់
ប្រើធ្វើឲ្យឆាប់ ។
១២៧-ឲ្យមានទំនៀម តំណាក់រៀងរាប
តាមផ្លូវឲ្យស្រាប ស្តេចយាងជើងគោក
នឹងយកទោសស្លាប់ ឲ្យធ្វើប្រញាប់
តាមព្រះហារទ័យ ។
១២៨-អស់រាស្ត្រទាំងឡាយ ឮហើយប្រញាយ

ភ័ន្តភាំងភិតភ័យ ខំធ្វើគ្មានឈប់
ទាំងយប់ទាំងថ្ងៃ តាមព្រះហឫទ័យ
ភិតភ័យស្មើគ្នា ។

១២៩-បានធ្វើរួចស្រេចទើបទៅទូលស្ដេច
នូវលោកចៅហ្វា ស្ដេចឲ្យអព្ភៃ
ត្បែសបៃនបិតា ក្មេកនិងពញា
យមរាជជើងទឹក ។

១៣០-សម្ដេចចៅហ្វារ នាំល្បួងលេលា
ជើងគោកគគឹក ពលពាលពេញពាស
ដើរដាស់ពន្លឹក ដំរីសេះសិក
ប៉ាំងក្លសលំយម ។

១៣១-ស្ដេចយាងកំសាន្ត ផ្គុំភ្លេងពុស៊ាន
សូរសព្ទរងំ ដរាបរៀងទៅ
តាមផ្លូវថ្លាធំ ស្ដេចយាងមិនខំ
ផ្ទុំគ្រប់ដំណាក់ ។

១៣២-លុះបានដល់ទៅ ព្រះពន្លាហៅ
កំពង់ល្បួងតាក ឲ្យរៀបរាំលេង
គ្រប់ល្បែងឥតអាក់ រាស្ត្រក៏គ្រឹកគ្រាក់
អរឯងទីទៃយ ។

១៣៣-តិចទើបចៅពញា យោមរាជជាតិជា
សៀមសុទ្ធធំក្រៃ អព្ភៃត្បែសបៃន
ជើងទឹកនោះនៃ ដល់ក្រោយបីថ្ងៃ
ដាក់ជើងកំពង់ ។

១៣៤-ស្ដេចឲ្យអស់ល្បែង ដេញដំផ្គុំភ្លេង
កំសាន្តព្រះអង្គ បានប្រាំពីរថ្ងៃ
ក្សត្រីថ្លៃឡើងគង់ បន្ទាយឧត្តង្គ
ដើមដែលដូនតា ។

១៣៥-ស្ដេចបានឡើងដល់ មន្ទីមណ្ឌល់
ទៀងទើបក្សត្រា ឲ្យហៅគុណគូរ
រកឫកពិលា និងសោយរាជា
គ្រប់គ្រងបូរី ។

១៣៦-ឲ្យរើសរកស្នំ ពាស់ពេញក្រមុំ
រូបរាងប្រិមប្រិយ៍ ល្អល្អះសក្តិសម
សឹងព្រហ្មចារ្យី រើសរៀបស្រេចស្រី
ស្នំស្និទ្ធទាំងឡាយ ។

១៣៧-កំណានសំអាង សំអាតរូបរាង
ទុនភ្លន់កៃក្រាយ ខ្ញុំណាន់បន្ទំ ឧត្តមពុំន្រាយ
កំណាន់ព្រះនាយ ព្រះសិទ្ធរស ។

១៣៨-កំណាន់ព្រះខាត ព្រះខ័នមហាក្ស័ត្រ
សឹងសម្មក់ពុះ កំពង់ពេញពាល
សៀមសារស្រេចស្រស់ ព្រះពាតព្រះពុស
ព្រះពានព្រះស្រី ។

១៣៩-ស្លៀកជងស្លៀកជាយ ស្បៃស្បិតបន្លាយ
ជំពូវទេសថ្មី កោសៃយកោសា
យម្មនាជាតី ជំពូវអន់ថ្មី
សាវសំពុតន្រាយ ។

១៤០-ខ្លះស្បៃបៃតង ដំណើរញៀញញៀង
ឯនអនកៃក្រាយ រំបៃបួងបទ
ស្រកុតអង្កាយ នាងខ្លះស្បៃស្វាយ
ភោភាវតាវតែង ។

១៤១-សំអាត់អស់ភ្នំ ត្រេងត្រុបស័ក្កសម
ល្អល្អះលើសលែង អណោកអណាន្ទ
ពេកពន់ឯកឯង សួសសមស័ក្តិសែង
លើសលែងលោកផង ។

១៤២-ឯអង្គអព្ភៃ ត្បែសបៃននោះនៃ
នាំបុត្រស្នេហ៍ស្នង ទៅថ្វាយព្រះបាទ
ននាដ្ឋច្បាស់ច្បង ឲ្យស្ដេចស្ដែងគ្រង
ជាទីពីធំ ។

១៤៣-ស្ដេចឲ្យរើសស្ត្រីមុខមាត់ប្រិមប្រិយ
ពាសពេញក្រមុំ សម្រាប់នាងនាដ្ឋ
ជាទេពីធំ ឲ្យសួនស័ក្កសម
ច្រើនក្រៃកន្លង ។ **(នៅមានត)**

# ប្រមាទ និង មិនប្រមាទ

ដកស្រង់ចេញពីសៀវភៅ **ស្នាព្រះហស្តក្រោយបង្អស់**
**នៃសម្តេចព្រះសុមេធាធិបតី ជួន ណាត**

**អប្បមាទោ អមតំ បទំ  បមាទោ មច្ចុនោ បទំ អប្បមត្តា ន មីយន្តិ យេ បមត្តា  យថាមតា ។**

សេចក្តីមិនប្រមាទ គឺការមិនធ្វេសស្មារតី ជាផ្លូវនៃអមតនិព្វាន សេចក្តីប្រមាទ គឺការធ្វេសស្មារតី ជាផ្លូវនៃមច្ចុ គឺការស្លាប់កើត - កើតស្លាប់ ជនទាំងឡាយណាមិនប្រមាទ ជនទាំងនោះឈ្មោះថាមិនស្លាប់ ជនទាំងឡាយណាប្រមាទ ជនទាំងនោះឈ្មោះថា ដូចជាស្លាប់ស្រេចទៅហើយ ។

## ពាក្យកាព្យឲ្យចាយចាំ បទភាកគត

វិក្តីប្រយ័ត្ន     មិនឲ្យភ្លាំងភ្លាត់
វិបត្តិស្មារតី     ជាផ្លូវអម្រឹត
វិសិដ្ឋឥតភ័យ     ឥតទុក្ខសោកអ្វី
កើតមានទៀតឡើយ ។

វិក្តីប្រហែស     ស្មារតីភ្លេចធ្វេស
គំនិតតោះតើយ     ជាផ្លូវមច្ចុ
ស្លាប់កើតឥតស្បើយ ឥតកោះឥតត្រើយ
វិលកើតវិលស្លាប់ ។

នរូអ្នកណា     មានចិត្តក្លៀវក្លា
ប្រញឹកប្រញាប់     ខំប្រឹងប្រព្រឹត្ត
ពិតតាមធម៌ច្បាប់     អ្នកនោះទោះស្លាប់
ហើយដូចនៅរស់ ។

នរូអ្នកណា     អាប់ឥតប្រាជ្ញា
ប្រមាទស្រស់ៗ     ភ្លេចភ្លាត់ស្មារតី
រាល់ថ្ងៃទាំងអស់     អ្នកនោះនៅរស់
ដោយដកដង្ហើម ។

ព្រះពុទ្ធទ្រង់ប្រាប់     ថាដូចជាស្លាប់
ស្រេចហើយគួរខ្ពើម ទោះបើនៅរស់
ដោយសារដង្ហើម     អ្នកប្រាជ្ញលោកផ្ទើម
ស្មើរក្អួតចង្អោរ ។

ជនផងគួរគិត     គួរផ្ចង់គំនិត
គួរកាត់គួរកោរ     គួរគេចចៀសវាង
គួររាងគួរស្ងោរ     រំងាស់ចិត្តចោរ
លួចប្លន់កុសល ។

យើងជាសាមញ្ញ     នៅមានក្តីក្នាញ់
គ្នាន់ខឹងរចល់     ក៏ពិតមែនហើយ
ប៉ុន្តែកុំខ្វល់     គួរប្រឹងតម្កល់
ចិត្តកុំប្រមាទ ។

គួរប្រុងប្រយ័ត្ន     ស្មារតីកុំភ្លាត់
កុំភ្លេចឱវាទ     អ្នកប្រាជ្ញទាំងឡាយ
មានព្រះជាអាទិ៍     កុំឲ្យឃ្លៀងឃ្លាត
ចាកធម៌សុចរិត ៕

*កំណាព្យ*

# ឈាមទឹកភ្នែកនៅព្រែកបាត្រាច

ឆ្នាំរោងចត្វាស័កជាក់គ្រាមួយ ពីរពាន់ប្រាំរយដប់ប្រាំបួន
លោកសង្ឃបង់ភេទហេតុពីយួន ចងពៀរគុំគួនក្បួនលាក់ពុត ។
ចាប់ព្រះសង្ឃប្រើធ្វើពលកម្ម ខួបគម្រប់ឆ្នាំតាមបែបបទ
ទីបីកុម្ភៈបក្សដិវត្តន៍ នៅក្នុងទសវត្សរ៍ឆ្នាំសាមសិប ។
ខែមាឃខ្យល់ធំផ្ដុំគ្រាប់ខ្សាច់ យួនមានអំណាចកាចឥតប្រៀប
បំបាត់ពូជខ្មែរកែទម្លាប់ សាសនាក្បួនច្បាប់សាបសូន្យសុង ។
ព្រះសង្ឃធំតូចពូជខ្មែរក្រោម យួនអាណានិគមទ្រោមឲ្យលង់
ជាន់លិចភក់ជ្រាំជំចុះផុង ទឹកជ្រោះអន្លង់អន្លង់ជ្រៅ ។
ខ្មែរបួសជាសង្ឃចង់រក្សា ពុទ្ធសាសនាការពារនូវ
ជាតិ ក្បួន ទម្លាប់ ច្បាប់ ឲ្យនៅ គង់វង្សញាតិផៅនៅជាម្ចាស់ ។
កាន់ខ្ជាប់សីលទានមានវិន័យ ភិក្ខុ នេន បួសថ្មីខ្មីឃ្មាតណាស់
សិក្សារៀនសូត្រស្លូតតាមព្រះ មិនមានមានះផ្លាស់ប្ដូរផ្សេង ។
ចេះស្នេហាជាតិមាតុភូមិខ្មែរ ព្រៃភ្នំទន្លេស្រែធំធេង
ភាសា វប្បធម៌ អក្សរជាតិយើង ប្រាង្គផ្ការុងរឿងថ្កើងនគរ ។
យួនឃើញដូច្នេះរិះរកល្បិច បំផ្លាញបំផ្លិចក្ដិចបាត់សូរ
បើពួកយួនទុកមុខជារីកវរ ថ្ងៃក្រោយបះបោរឈរប្រឆាំង ។
ចាប់សង្ឃទូទៅនៅក្នុងដៃ ឲ្យជីកប្រឡាយថ្ងៃចែងចាំង
ដីស្ងួតហួតហែងផ្សែងក្ដៅខ្លាំង សង្ឃអស់កម្លាំងតាំងរងគ្រោះ ។
បបរពេលព្រឹកទឹកត្រីប្រៃ ចង្ហាន់ពេលថ្ងៃបាយជ្រក់ច្រោះ
ចូនជាបាយឆៅក្ដៅចុកពោះ ជុះមួលរាករុះចុះស្លេកខ្លួន ។
ទឹកដីជីកព្រែកចែកកាត់វាស់ កប់កាយជីកគាស់បោះជញ្ជូន
សែងដីឡើងលើធ្វើខ្ពបយួន សង្ឃមិនជាមួនជួនគ្រុនឈឺ ។
អង្គខ្លះចុកពោះលស់គ្រុនចាញ់ ផ្កាសាយស្រៀវស្រាញសង្កាញ់សង្កើ
ផ្សាពងអណ្ដាតស្កាតមាត់លើ ក្ដៅពេកភ្នែកស្លឹមើលមិនបាន ។
ក្ដៅខ្លាំងឥតប្រៀបហៀបនឹងឆេះ ស្ទើរបែកព្រះកេសប្រេះសព្វប្រាណ
រាល់ថ្ងៃគ្រប់ព្រឹកទឹកគ្មានឆាន់ អត្តខាត់ចង្ហាន់មិនគ្រប់គ្រាន់ ។
សឹងផ្ទាល់នឹងដីភ័យថ្លាន់ពស់ ក្អែបខ្ជួយសុចមូសចុះរាប់ពាន់
រោមខាំទិចអុចរត់មិនទាន់ គ្រោះកាចអាសន្នព័ន្ធកែងទៀត ។
យប់យន់ត្រជាក់ផ្លាក់សន្សើម ព្រះពាយដង្ហើមផ្ដើមចង្អៀត
សំឡឹងទៅលើមើលផ្កាយព្រាត នឹកសាសនាជាតិញាតិខ្មែរក្រោម ។
ជិតបួនរយឆ្នាំចាំពុំភ្លេច នឹកឃើញជានិច្ចកិច្ចឧត្ដម
ថ្ងៃរំដោះជាតិមាតុភូមិ ពីអាណានិគមទាមទារសេរី ។
ធ្វើការនឿយហត់អត់ទឹកស្រង់ ត្រៃចីពរស្បង់ផង់ភក់ដី
ទឹកជ្រាំល្បាយល្បាប់ឆ្អាបអាត្រី អាក្រក់ឥតបីអ្វីប្រៀបស្មើ ។
ក្រឡេកមើលទៅនៅវាលស្រែ សង្ឃឥតឈប់ល្ហែប្រែប្រះធ្វើ
អង្គខ្លះគាស់កាប់ចាប់សែងដើរ ពីក្រោមឡើងលើឈើនៅស្មា ។
ប្រឡាក់តែភក់មុខស្រមាម ញើសហូរហោមតាមភក្ត្រា
ពិនិត្យមើលផ្ទាល់ស្គាល់នេត្រា កុំអីចោទថាមថ្លាផ្សាត ។
ឃើញសង្ឃធ្វើការថាលែងចេញ កើតទុក្ខទោម្នេញវេញចិត្តក្រោធ
យួនមិនរអែងក្រែងឱនកោត ធ្វើបាបសង្ឃស្លូតពុតពួកយួន ។
នេនថាំង ជ្រៃសួរថូរស្រស្រុន ក្ដៅរងារគ្រុនធ្ងន់ប្រមាណ
ក្របាយខ្លាំងពេកស្រែកសុំទឹកឆាន់ ក្រែងត្រជាក់ប្រាណបានស្បើយខ្លះ ។
សឹងនៅវាលស្រែក្បែរប្រឡាយ ហាលកណ្ដាលថ្ងៃកាយក្រាលក្រាស់
សរីរៈបេះដូងទ្រូងចុកណាស់ ប្រឹងវារកខ្វេសកខ្វាសប្រាសដួលទៅ ។
មុននឹងចែកឋានបានប្រាប់នេន ទ្រូងគ្នាចុកណែនសែនក្តួលក្ដៅ
មានរូបសង្ខារថាម៉េចត្រូវ កើតស្លាប់សោកសៅហៅមិនទៀង ។
នែ ! នេនជ្រៃសួរគ្រូតែមួយ តទៅថ្ងៃក្រោយជួយកុំល្អៀង
មើលថែរក្សាតាគ្រូយើង ព្រះជន្មច្រើនឡើងថ្កើងសាសនា ។
គន់មើលប្រឡាយផ្លាយសន្លឹម កុំអស់សង្ឃឹមត្រឹមរូបគ្នា
លះលាចាកលោកយកមរណា លាអស់ខេមរាតាញាតិញោម ។
ព្រែកជីកបាត្រាចអាចជាសាក្សី ដឹងអន្សតិរ្ដីយ៍ក្រញីខ្មែរក្រោម
ធ្វើបាបលោកសង្ឃចង់ឲ្យញ៉ម ទឹកដីខ្មែរក្រោមពមលេបបាត់ ។
យួនបំពួនពុតភូតល្បាញល្បី លួចប្លន់ទឹកដីព្រៃសម្បត្តិ
ត្រី សមុទ្រធំ ភ្នំប្រាសាទ រំលាយបង់បាត់កាត់យកបាន ។
ប្រវត្តិសាស្ត្រច្បាស់កត់ទុក ចារឈ្មោះគូរមុខពួកសាមាន្យ
ឆ្នាំចិតសិបប្រាំចាំជាក់ស្បាន យួនព្រួតរំខានបានចាប់សង្ឃ ។
ថាច់រាជមេគណបុណ្យស័ក្ដិធំ យួនចាប់ដាក់ឃុំម្ដុំវាលត្បូង
ថាច់ស្នែអង្គគង់ទីជិតក្រុង គ្រូស្រស់មេរងគង់ជាប់ដៃ ។
វត្តដំបងពាក់ស្នាក់ព័ទ្ធជុំ ថាច់ចន្ទជាភិរម្យចោមចាប់ថ្លៃ
សម្រាតចាប់ផ្សឹកដឹកអូសដៃ ផាក់ទាត់រំផរៃម៉្ងៃបួនត ។
នៅមានច្រើនទៀតញាតិជួយចាំ រឿងសោកនាដកម្មតាមយួនបង្ក
ពេលឥឡូវនឹងដឹងអាក្រក់ល្អ យួនជាឃាតករបន្តសម្លាប់ ។
ប្រឡាយបាត្រាចកាច់យកសង្ឃ កូននេនមួយអង្គបង់យ៉ាងឆាប់
ទ្រូងខ្មែរចុកណែនសែនឈឺចាប់ សរសេររ៉ាយរ៉ាប់ប្រាប់មិនអស់ ។
ប្រឡាយបាត្រាចកាចឫស្យា ប្រឡាយប្រហារអារកាត់ចោះ
ពន្លះពុះទ្រូងរូងទាំងរស់ ជាតិខ្មែរស្រីប្រុសលស់ព្រលឹង
សាច់ឈាមក្រហមឡាំលាយឆ្អឹង ពូនគរគោកបឹងរឹងជាថ្ម ៕

ថាច់ សុមេធ




**បញ្ញាសជាតក**
**រឿងទី ១៣**

*ជាស្នាដៃនិពន្ធរបស់លោក* ***ញ៉ុក ថែម***
*បោះពុម្ពលើកទី ១ នៅភ្នំពេញ ឆ្នាំ ១៩៥៩*

# រឿងទុក្កម្មានិកៈ

ក្នុងកាលកន្លងមកយូរអង្វែងហើយនោះ មានកុដុម្ពីក៍ម្នាក់នៅទីជនបទ នៃខេត្តដែនក្រុងពារាណសី មានបុត្រម្នាក់ឈ្មោះទុក្កម្មានិកៈ ។ តមកបុរសជាបិតាមានជម្ងឺឈឺជាទម្ងន់ មុនស្លាប់បានហៅទុក្កម្មានិកមាណពជាបុត្រមកផ្តាំថា "ហៃកូនមាសឪពុក បាឯងកុំយកស្រីមេម៉ាយបីដងជាប្រពន្ធ កុំយកបុរសបួសបីដង សឹកបីដងជាសំឡាញ់ កុំសេពគប់ព្រះរាជាដែលឥតពិចារណា" កុដុម្ពីក៍ជាបិតាបានពោលផ្តាំពាក្យបីម៉ាត់នេះហើយក៏អនិច្ចកម្មទៅ ។

ថ្ងៃមួយមានស្រីមេម៉ាយបីដងម្នាក់ មកសំដែងអាការស្និទ្ធស្នាលគួរឲ្យចាប់ចិត្តស្នេហា ។ មាណពបាននឹកឃើញបណ្តាំរបស់បិតាដែរ តែចង់សាកល្បងមើល តើជាមានផលពិតមែនឬមិនមែនទេ ។ ដើម្បីឲ្យយល់ការណ៍ជាក់ស្តែង អ្នកក៏ទទួលយកស្រីមេម៉ាយបីដងនោះធ្វើជាភរិយា ។ តមកទៀតមានបុរសបួសបីដង ចូលមករកអ្នក ៗ ក៏ទទួលយកជាមិត្រសំឡាញ់ ដើម្បីពិសោធពាក្យបណ្តាំរបស់បិតា ។

សម័យមួយ សុវណ្ណហង្សរបស់ព្រះរាជា កំពុងត្រាច់ដើរក្បែរមាត់ស្ទឹង ។ មាណពក៏ចាប់យកសុវណ្ណហង្ស ហើយតាំងដីករណ្តៅមួយ ហើយដាក់ហង្សក្នុងរណ្តៅនោះ យកជាលគ្របបំពោកភក់ ទុកប្រហោងតូច ៗ សម្រាប់ឲ្យហង្សដកដង្ហើមបានស្រួលហើយអ្នកវិលមកផ្ទះសម្លាប់ហង្ស ១ ផ្សេងទៀតចិញ្ច្រាំស្លជាស្រេចនៅពេលដែលនាងមេម៉ាយបីដងទៅផ្សារ ។ បន្តិចលេចភរិយាមកពីផ្សារ អ្នកក៏និយាយប្រាប់ថា "បងចាប់សុវណ្ណហង្សរបស់ព្រះរាជាចិញ្ច្រាំស្លស្រេចទៅហើយ ។ ភរិយាតាំងស្តីបន្ទោសប្តីថា "អ្នកមិនដឹងទេឬ អំពើនេះមានទោសធ្ងន់ណាស់" ។

តមកបន្តិច ក៏មានការច្របូលច្របល់កើតឡើង ដោយហេតុបាត់សុវណ្ណហង្សស្តេច ៗ ត្រាស់ឲ្យឃោសនាផ្សាយដំណឹងថា "អ្នកណាមួយអាចដឹងថា សុវណ្ណហង្សបាត់រូបទៅដោយហេតុម្តេច ទ្រង់នឹងប្រទានមាសមួយពាន់ដំឡឹង" ។ ឯភរិយាទុក្កម្មានិកបុរស កំពុងតែចង់បានប្តីថ្មីទៀតផង ក៏ឆ្លើយតបអាមាត្យអ្នកឃោសនាថា "ខ្ញុំដឹងហេតុដែលបាត់សុវណ្ណហង្ស របស់ស្តេច" ហើយនិយាយប្រាប់អាមាត្យនោះ ដោយសព្វគ្រប់ ។ អាមាត្យក៏ចាប់ចងបុរសប្តី ដោយចំណង ៥ ប្រការហើយនាំទៅថ្វាយស្តេច ៗ ត្រាស់បង្គាប់ឲ្យនាំខ្លួនទៅសម្លាប់ក្នុងថ្ងៃនោះឯង ។ ឯបុរសបួសបីដង សឹកបីដងជាសំឡាញ់ឥតបានជួយឈឺឆ្អាលអ្វីសោះ ត្រឡប់បែរជានិយាយសុំសំពត់ស្លៀក ពីទុក្កម្មានិកបុរសវិញថា "សំឡាញ់អើយ ! សំពត់យើងរហែករយ៉ៃ សំឡាញ់ជាប់ទោសត្រូវសម្លាប់ សំឡាញ់ឲ្យសំពត់ស្លៀកនោះមកយើងវិញទៅ" ។ ថាហើយក៏ភើបយកសំពត់ស្លៀក សំពត់ដណ្តាប់អ្នកទៅ ។ នៅគ្រាដែលពួកពេជ្ឈឃាតកំពុងបណ្តើរអ្នកយកទៅសម្លាប់នោះ អ្នកទន្ទេញថា "បើហង្សស្លាប់ខ្ញុំក៏ស្លាប់ បើខ្ញុំមិនស្លាប់ ហង្សក៏មិនស្លាប់ដែរ" ។

ពួកពេជ្ឈឃាតក៏និយាយគម្រាមថា "ហង្សរបស់ស្តេចប្រស្នែងកាប់ស្ងួស៊ីអស់ទៅហើយ មានហង្សពីណារស់ឡើងវិញ" ហើយនាំខ្លួនអ្នកទោសចេញទៅ សំដៅទ្វារទិសខាងកើត ។ ជួនជាថ្ងៃនោះពួកឆ្មាំទ្វារបិទទ្វារព្រះនគរពេលថ្ងៃរសៀល ។ ពេជ្ឈឃាតសុំឲ្យបើកទ្វារ ។ ឆ្មាំទ្វារឆ្លើយថា "បើព្រះរាជាមិនទាន់ជំនុំជំរះទោសទេ យើងនឹងបិទទ្វារអស់កំណត់បីថ្ងៃ ព្រោះក្រែងព្រះរាជាឲ្យសម្លាប់មនុស្សមិនមែនជាចោរកំណាច នឹងនាំឲ្យបានក្តីក្តៅក្រហាយស្តាយក្រោយមហិមាដូចបុរសប្តីប្រពន្ធសម្លាប់ស្ការ ។ ពេជ្ឈឃាតសុំឲ្យឆ្មាំទ្វារដំណាលរឿងនោះ ។ ឆ្មាំទ្វារក៏ដំណាលរឿងនោះថា ៖

"កាលណោះមានស្វាមីភរិយាពីរនាក់ នឹងកូនប្រុសតូច

មួយ ។ អ្នកទាំងពីរចិញ្ចឹមសត្វស្ការមួយឲ្យនៅចាំផ្ទះ ខ្លួនឯងទាំងពីរចេញទៅធ្វើការឯស្រែ ។ ថ្ងៃមួយពស់មួយលូនចូលមកចឹកទារកនោះស្លាប់ទៅ ឯស្ការក្រឡេកឃើញពស់ ក៏ស្ទុះចូលទៅប្រយុទ្ធនឹងពស់នោះ ហើយបានខាំពស់ដាច់ចេញជាកំណាត់ ៗ ពស់ក៏ស្លាប់ ទារក់ក៏ស្លាប់ ។ ស្ការរត់ទៅឲ្យដំណឹងដល់ម្ចាស់វាឯស្រែ ។ ប្ដីប្រពន្ធមិនយល់សេចក្ដី ដោយបានឃើញខ្លួនស្ការប្រឡាក់ឈាម ក៏ស្មានថា ស្ការខាំកូនរបស់ខ្លួនក៏ចាប់ដងរនាស់សំពងស្ការនោះត្រាតែស្លាប់ទៅ ។ ប្ដីប្រពន្ធក៏នាំគ្នារត់មកមើលផ្ទះ បានឃើញខ្មោចពស់ជាកំណាត់ ៗ កៀនជញ្ជាំងទើបដឹងថាកូនខ្លួនត្រូវពស់ចឹកស្លាប់ ក៏នាំគ្នាយំសោកស្ដាយកូនស្ដាយស្ការដែលខ្លួនបានសម្លាប់ដោយឥតពិចារណា” ។ ហេតុនេះហើយបានជាយើងមិនយល់ព្រមបើកទ្វារឲ្យ ។

ពេជ្ឈឃាត ក៏នាំអ្នកទោសទៅទ្វារនគរខាងត្បូង ។ ពួកឆ្មាំទ្វារនគរទិសខាងត្បូង ក៏បាននិយាយដូចឆ្មាំទ្វារខាងកើតដែរ ហើយថា អំពើដែលមិនបានពិចារណាជាមុន ច្រើនតែបានក្ដីក្ដៅក្រហាយស្ដាយក្រោយ ដូចរឿងព្រានប្រមាញ់សម្លាប់ខ្លែង ។ ពេជ្ឈឃាតក៏សុំឲ្យដំណាលរឿងនោះ ឆ្មាំទ្វារក៏ដំណាលថា ៖

មានព្រានប្រមាញ់ម្នាក់បានចិញ្ចឹមសត្វខ្លែងមួយ ។កាលណាព្រានចេញទៅបរបាញ់សត្វបក្សី ខ្លែងក៏ទៅជាមួយដែរ ។ ថ្ងៃមួយបុរសព្រានស្រេកទឹកខ្លាំង ក៏ចុះទៅផឹកទឹកក្នុងស្ទឹង មួយ នៅទីនោះមានពស់មានពិសមួយ ប្រុងលោតមកចឹកនាយ ព្រាន ។ ឥតបានឃើញសោះ ឯសត្វខ្លែងបានក្រឡេកឃើញអាការដូច្នោះ ក៏ទទះស្លាបកញ្ជ្រាកទឹក កុំឲ្យម្ចាស់វាចុះទៅផឹកទឹក ។ ឯបុរសស្រេកខ្លាំង ប្រឹងតែមុលចុះទៅផឹក បានឃើញខ្លែងមកក្លែងធ្វើមិនឲ្យផឹកទឹកកើត ក៏ខឹងខ្លាំង ហើយប្រហារក្បាលខ្លែងដោយដងធ្នូស្លាប់ទៅ ។ បុរសឈ្មោកផឹកទឹកម្ដងទៀត ពស់ក៏ហក់ភ្លែតចឹកចំភ្នែកម្ខាងខ្វាក់ទៅ ។ ព្រានប្រមាញ់ក៏ស្រែកទ្រហោយំស្ដាយសត្វខ្លែង ដែលមានស្វាមីភក្ដិ ថែមទាំងខូចភ្នែកម្ខាងទៀតផង” ។

ពេជ្ឈឃាតក៏នាំអ្នកទោសទៅទ្វារទិសខាងលិច ។ ពួកឆ្មាំទ្វារក៏បាននិយាយសាសព្វ ប្រាប់ហេតុដែលខ្លួនមិនព្រមបើកទ្វារដូចអ្នកមុន ៗ ដែរ ឯរឿងដំណាលមានដូចតទៅនេះ ៖

“កាលណោះ មានព្រះរាជាមួយព្រះអង្គ ព្រះនាមព្រះបាទព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងនគរពារាណសី មានព្រះរាជធីតាមួយអង្គព្រះនាមសុន្ទរា ។ ព្រះនាងតែងទៅកក់ស្រង់ក្នុងស្រះបោក្ខរណី មានឆ្កែចិញ្ចឹមមួយតែងតែដើរតាមព្រះនាងជានិច្ច ។ មានបុរសជាសត្រូវម្នាក់ បានចងគំនុំព្យាបាទព្រះរាជាព្រះវរបិតាព្រះនាង បានលបលួចបង្កប់ចម្រូងក្បែរមាត់ស្រះបោក្ខរណី ដើម្បីឲ្យជង់រាជបុត្រី ។ ឯឆ្កែបានឃើញហេតុភេទដូច្នោះ ក៏រត់ទៅស្ទាក់ផ្លូវព្រះរាជធីតា ដែលកំពុងយាត្រា តែព្រះរាជធីតាបេះតែទ្រង់ចបេសទៅមុខទៀតដល់មាត់ស្រះ ត្រូវនឹងចម្រូងសោយទីវង្គតទៅ ។ ឯឆ្កែក៏ស្ទុះទៅពាំយកគ្រឿងអលង្កាទៅដាក់ក្បែរព្រះរាជា ដើម្បីជាដំណឹង ។ ឯព្រះបាទព្រហ្មទត្តបានទ្រង់ឃើញប្រដាប់ប្រដាព្រះរាជធីតា ក៏ទ្រង់គិតស្មានថា ឆ្កែនេះខាំសម្លាប់កូនអញហើយពាំយកប្រដាប់ប្រដាមក ទើបទ្រង់ឲ្យគេសម្លាប់ឆ្កែនោះភ្លាមទៅ ។ តមកបន្តិចទ្រង់បានជ្រាប់ច្បាស់ថា ព្រះរាជបុត្រីសុគតដោយហេតុដទៃទេ ក៏ទ្រង់កន្សែងវិយោគសោកស្ដាយមហិមា ព្រោះតែមិនបានពិនិត្យពិចារណាជាមុន” ។

ពេជ្ឈឃាតក៏បាននាំអ្នកទោសទៅទ្វារទិសខាងជើង ។ ពួកឆ្មាំទ្វារមិនព្រមបើកទ្វារឲ្យ ដោយអាងហេតុផលដូចអ្នកមុន ៗ នោះដែរ ហើយបាននិទានរឿងពីសំឡាញ់ពីរនាក់ ។

មានសេចក្ដីដំណាលថា មានបុរសជាសំឡាញ់គ្នាពីរនាក់ ហើយស្រឡាញ់គ្នាណាស់ ម្នាក់នៅស្រុកខាងលិច ម្នាក់ទៀតនៅស្រុកខាងកើត ។ ឯសំឡាញ់នៅស្រុកខាងលិច បានទៅលេងផ្ទះសំឡាញ់នៅស្រុកខាងកើត ។ សំឡាញ់ស្រុកខាងកើតនោះ បានចិញ្ចឹមឆ្កែមួយជាទីស្រឡាញ់ពេញចិត្តណាស់ ប៉ុន្តែទីទ័លក្ររកអ្វីនឹងឲ្យសំឡាញ់គ្មាន ក៏បានលើកឆ្កែនោះឲ្យទៅសំឡាញ់ស្រុកខាងលិច ៗ ក៏បបោសអង្អែលឆ្កែ ថ្លែងសេចក្ដីអរគុណហើយនាំទៅគេហដ្ឋានរបស់ខ្លួន ។

បំណោរតមក បុរសនោះចងខ្សែយ៉ាងល្អនឹងកឆ្កែ ហើយបញ្ជូនទៅម្ចាស់ដើមវិញ ដើម្បីឲ្យដំណឹងសុខទុក្ខរបស់ខ្លួន ។ ឆ្កែក៏រត់ទៅរកម្ចាស់ដើម ៗ បានឃើញខ្សែល្អពាក់នៅកឆ្កែ ក៏គិតស្មានថាឆ្កែនេះលួចទ្រព្យសំឡាញ់ខ្លួនរត់មក ក៏ប្រហារឆ្កែនោះត្រាតែស្លាប់ទៅ ។ ឯសំឡាញ់នៅស្រុកខាងកើត មិនឃើញឆ្កែ

ត្រឡប់មកវិញក៏នឹងសង្ស័យ ទើបទៅសួរដំណឹងឆ្កែនោះ ។ លុះបាន ដំណឹងថាឆ្កែនោះស្លាប់ទៅហើយ ដោយអំពើមិនសមហេតុផល ។ បុរសទាំងពីរនាក់ ក៏កើតទុក្ខក្តៅក្រហាយស្តាយក្រោយខ្លាំងណាស់ ។

កាលពេជ្ឈឃាតនឹងឆ្មាំទ្វារនិយាយឆ្លើយឆ្លងគ្នា ដូចបានពណ៌នាមកនេះ រាត្រីក៏ភ្លឺស្វាងឡើង ។ ពេជ្ឈឃាតក៏នាំអ្នកទោសត្រឡប់ទៅក្រាបទូលព្រះរាជាវិញ។ ព្រះរាជាទ្រង់ស្តី បន្ទោសថា “អញឲ្យយកទៅសម្លាប់ ម្តេចក៏នាំវាត្រឡប់មកវិញ” ។ អាមាត្យក៏ក្រាបបង្គំទូលតាមដំណើរសព្វគ្រប់ ។ ព្រះរាជាក៏ត្រាស់សួរទុក្កម្មានិកបុរសថា “នៃប្រុស្តែង ឯងមានរឿងចង់តវ៉ាដូចម្តេចខ្លះ ? ទុក្កម្មានិកបុរសក៏ក្រាបបង្គំទូលថា “សូមទ្រង់ព្រះមេត្តាប្រោស ការដែលទូលបង្គំបានធ្វើមកនេះ ប្រយោជន៍ចង់សាកល្បងពាក្យបណ្តាំបិតារបស់ទូលព្រះបង្គំប៉ុណ្ណោះ ។ សូមទ្រង់ព្រះមេត្តាប្រោស សុវណ្ណហង្សរបស់ព្រះអង្គ ទូលព្រះបង្គំមិនបានសម្លាប់ទេ ទូលបង្គំលាក់ទុកនៅទីត្រង់ណោះសូមទ្រង់ជ្រាប” ។ ស្តេចត្រាស់ថា “បើប្រុស្តែងមិនបានសម្លាប់ហង្សយើង ចូរទៅនាំយកមកឲ្យយើងក្នុងកាលឥឡូវនេះចុះ” ។ បុរសក៏នាំយកហង្សនោះមកថ្វាយព្រះរាជាក្នុងខណៈនោះឯង ។

ព្រះរាជាទ្រង់ត្រាស់សួរអ្នកអំពីបណ្តាំរបស់បិតាអ្នកមុនអនិច្ចកម្ម ។ អ្នកបានក្រាបទូលរឿងរ៉ាវរបស់ស្រីមេម៉ាយប្តីបីដែលបានមកជាប្រពន្ធអ្នកនឹងសំឡាញ់ដែលបួសបីដង សឹកបីដង ឲ្យបានទ្រង់ជ្រាបសព្វគ្រប់ ។ ព្រះរាជាមានព្រះទ័យសោមនស្សណាស់ បានទ្រង់ប្រទានដំណែងឧបរាជដល់អ្នក ប៉ុន្តែដោយអាងដល់បណ្តាំបិតាដែលពោលទុកថា “នគរណាដែលមានស្តេចគ្រងរាជ្យឥតពិចារណា កុំឲ្យអាស្រ័យនៅក្នុងនគរនោះឡើយ” ហើយអ្នកក្រាបបង្គំទូលលាព្រះរាជា ចេញទៅនៅនគរតក្កសិលា នៅនគរនោះ អ្នកបានប្រកបដោយជោគជ័យសិរីសួស្តីមានក្តីសុខ សុភមង្គលខ្ពង់ខ្ពស់ជានិច្ចតរៀងទៅ ៕

# វេទិកា គំនិតជាតិ

ប្រិយមិត្តអ្នកអានជាទីមេត្រី!

ព្រឹត្តិបត្រ កម្ពុជាក្រោម បានចាប់កំណើតឡើងក្នុងខែមករា ឆ្នាំ ២០០៤ រហូតមកទាល់នឹងបច្ចុប្បន្ននេះ បានចុះផ្សាយដល់លេខទី ១៤ នៃ ឆ្នាំទី ២ ហើយ ។ រយៈពេលកន្លងមកនេះ ក្រុមការងារយើងខ្ញុំបានខិតខំធ្វើការយ៉ាងមមាញឹក ក្នុងការប្រមូលព័ត៌មាន និងឯកសារសំខាន់ ៗ មកចុះផ្សាយដើម្បីឆ្លើយតបទៅនឹងតម្រូវការ របស់មិត្តអ្នកអាននៅជុំវិញពិភពលោក ។

ដោយសារមានការគាំទ្រ ពីសំណាក់ប្រិយ-មិត្តអ្នកអានចំពោះព្រឹត្តិបត្រយើងខ្ញុំ ក៏ដូចជាការការគាំទ្រគោលនយោបាយ របស់សហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងបុព្វហេតុស្វ័យសម្រេចវាសនាខ្លួន យើងខ្ញុំតែងទទួលបាននូវសារលិខិតដាស់តឿន លើកទឹកចិត្តមតិរិះគន់ស្ថាបនា ព្រមទាំងការឧបត្ថម្ភជាថវិកាសម្រាប់បោះពុម្ពផ្សាយជារៀងរាល់ខែផង ។

ចាប់ពីលេខទី ១៥ តទៅ យើងខ្ញុំមានកិត្តិយសបើកបន្ថែមនូវទំព័រវេទិកាអ្នកអាន ដែលមានចំណងជើងថា “**គំនិតជាតិ**” សម្រាប់ចុះផ្សាយនូវមតិយោបល់របស់មិត្តអ្នកអានទាក់ទងទៅនឹងបញ្ហា ដែលជនរួមជាតិខ្មែរនៅកម្ពុជាក្រោមកំពុងជួបប្រទះ ក៏ដូចជាបញ្ហាទាក់ទងទៅនឹងគោលនយោបាយ និងសកម្ម-ភាពរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ។

រាល់មតិយោបល់សូមផ្ញើមកកាន់ ៖

P.O. Box 2569, Worcester, MA 01613, USA,

E-mail: kkfnewsletter@yahoo.com

សូមប្រិយមិត្តអ្នកអាន ទទួលនូវសេចក្តីស្រឡាញ់រាប់អាន និងសេចក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុតពីយើងខ្ញុំ ។

សូមអរគុណ

# រាយការណ៍ស្តីអំពីការរំលោភសិទ្ធិមនុស្ស

***Fax: 41-22-917-0092-Geneva-Switzerland-*** *ព័ត៌មានទាន់ហេតុការណ៍ ២៤ ម៉ោងលើ ២៤ ម៉ោង*

ការរំលោភសិទ្ធិមនុស្ស កើតមានជាបន្តបន្ទាប់ ដែលបង្កឡើងដោយរដ្ឋាភិបាលយួនកុម្មុយនិស្ត មកលើប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ហើយត្រូវបានសហគមន៍អន្តរជាតិធ្វើព្រងើយកន្តើយ មិនបានយកចិត្តទុកដាក់ ឬចាត់វិធានការ ដើម្បីទប់ស្កាត់ អស់ជាច្រើនទសវត្សរ៍មកហើយ ។ រហូតមកដល់ពេលនេះ ដោយសារកិច្ចខិតខំប្រឹងប្រែងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) បានធ្វើឲ្យខ្មែរក្រោម មានឈ្មោះបោះសម្លេងលើឆាកអន្តរជាតិ គួរជាទីមោទនៈ ។ មិនត្រឹមតែប៉ុណ្ណោះ បណ្តារដ្ឋាភិបាល ក៏ដូចជាអង្គការអន្តរជាតិនានា កំពុងផ្តោតការយកចិត្តទុកដាក់ជាសំខាន់ ចំពោះបញ្ហាខ្មែរក្រោម ។

របាយការណ៍ ស្តីអំពីការរំលោភសិទ្ធិមនុស្សលើខ្មែរកម្ពុជាក្រោមដំបូង ត្រូវបានអង្គការសហប្រជា-ជាតិធ្វើឡើងក្នុងឆ្នាំ ១៩៩៨ (E/CN.4/1999/58/Add.2 "ស្តីអំពីសិទ្ធិនយោបាយ និងសិទ្ធិប្រជាពលរដ្ឋរួមទាំងបញ្ហារំលោភសាសនាផង") ។ ទោះបីមានការរារាំងពីអាជ្ញាធរយួនកុម្មុយនិស្តយ៉ាងណាក៏ដោយ ក៏អ្នករាយការណ៍ពិសេស នៃអង្គការសហប្រជាជាតិ បានពុះពារ រហូតបានចូលទៅដល់សហគមន៍ខ្មែរកម្ពុជាក្រោម ហើយបានឃើញផ្ទាល់នូវអំពើព្រៃផ្សៃផ្សេង ៗ ក្នុងគោលបំណង ដើម្បីបំបាត់វប្បធម៌ សាសនាខ្មែរ និងការរំលោភយកដីធ្លី វត្តអារាមរបស់ប្រជាពលរដ្ឋខ្មែរក្រោមពីសំណាក់អាជ្ញាធរយួនកុម្មុយនិស្ត ។

ឥឡូវនេះ ខ្មែរក្រោមអាចរាយការណ៍ជូនអង្គ-ការសហប្រប្រជាជាតិ អំពីការរំលោភសិទ្ធិមនុស្ស ២៤ ម៉ោងលើ ២៤ ម៉ោង តាមរយៈបណ្តាញព័ត៌មានទាន់ហេតុការណ៍ ដែលមានលេខហ្វាក់ (Fax): 41-22-917-0092 នៅក្រុងហ្សឺណែវ ប្រទេសស្វីស (Switzerland) ។ បណ្តាញព័ត៌មានទាន់ហេតុការណ៍នេះមានសារៈសំខាន់ ក្នុងការទប់ស្កាត់នូវរាល់អំពើរំលោភសិទ្ធិមនុស្សទាំងឡាយ ដែលបង្កឡើងពីសំណាក់អាជ្ញាធរយួនកុម្មុយនិស្ត តាមរយៈការទាក់ទងជាមួយបណ្តាញពិសេសនៃឧត្តមស្នងការសិទ្ធិមនុស្ស ។

ព័ត៌មាន ដែលត្រូវរាយការណ៍ តាមរយៈបណ្តាញនេះ គឺស្ថិតក្នុងគោលការណ៍ទាំង ៥ នៃកម្មវិធីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ៖

-ស្ថានភាពធ្ងន់ធ្ងរអំពីបញ្ហាសិទ្ធិមនុស្ស ។

-ស្ថានភាពវិវត្ត ដែលត្រូវការអន្តរាគមន៍ពីឧត្តមស្នងការ ។

-បេសកកម្មស៊ើបអង្កេត ដោយអ្នករាយការណ៍ពិសេស និងក្រុមការងារ ។

-សកម្មភាព ដែលតាមដានដោយឧត្តមស្នង-ការ ដើម្បីផ្តល់អនុសាសន៍ ធ្វើឡើងដោយអ្នករាយ-ការណ៍ពិសេស និងក្រុមការងារ ។

-ការខិតខំអនុវត្តការងារអង្គការ ដែលមានកិច្ចព្រមព្រៀងជាគ្រឹះ ហើយផ្អែកផ្តល់ដំបូន្មាន និងជំនួយការបច្ចេកទេស នៃបណ្តារដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ៕



ពីឆ្វេងទៅស្តាំ លោក **ថាច់ ង៉ុកថាច់**, លោក បណ្ឌិត **ចូស្វ័រ ក្វាហ្វើ**, និងលោក **ចៅ វៀប** ក្នុងសន្និបាតសហព័ន្ធខ្មែរកម្ពុជាក្រោម